# អ្នកនាំសារ THE MESSENGER

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១១ | សម្រាប់ខែ មិថុនា ឆ្នាំ ២០១៩ | តម្លៃលក់ ១០០០រៀល | លេខ #១២១


# ប្រេងកាត! ចេះតែឮប៉ុន្តែមិនដឹងជានៅពេលណា? រោងចក្រចម្រាញ់ប្រេងកាតក៏មិនដឹងសាងសង់ដល់ណា?

មកដល់ពេលនេះប្រជាពលរដ្ឋកម្ពុជានៅតែមានចម្ងល់ថា តើពេលណាបានពួកគេបាន ទទួលព័ត៌មានពិតប្រាកដអំពីប្រេងកាត ក្រោយពេលដែលពេលវេលានៃការទទួលតំណក់ប្រេងដំបូង គឺត្រូវពន្យាពេលជាបន្តបន្ទាប់ និងមិនទាន់ឃើញសមិទ្ធផលអ្វី ក្រៅតែពីកិច្ចប្រជុំ កិច្ចព្រមព្រៀង។ > ទំព័រ ១០-១១



## វិចារណកថា

# «យើងជាសរីរៈរវាងគ្នានិងគ្នា»



រូបភាព៖ Freepik

ដោយ៖ លី សុវណ្ណា

បងប្អូនជាទីស្រឡាញ់ អ្នកនាំសារ សូមអរគុណបងប្អូនដែលបានគាំទ្រកន្លងមក និងបានផ្តល់យោបល់មកអ្នកនាំសារផងដែរ។ បងប្អូនខ្លះបានលើកឡើងនូវចំណុចមួយចំនួន ដើម្បីឲ្យអ្នកនាំសាររំលេចចេញឡើង គឺថា ក្នុងមួយរយៈចុងក្រោយនេះប្រទេសកម្ពុជា បានអភិវឌ្ឍយ៉ាងឆាប់រហ័ស ទាំងសំណង់អាគារ និងហេដ្ឋារចនាសម្ពន្ធនានា ផ្លូវថ្នល់ក៏បានកាន់តែល្អ ជីវភាពរបស់បងប្អូនក៏កាន់តែប្រសើរ បើទោះបីជាបងប្អូនមួយចំនួននៅជួបការលំបាក។ ជាការពិត ការលើកឡើងបែបនេះគឺត្រឹមត្រូវ ព្រោះថាការរស់នៅរបស់មនុស្សម្នាក់ៗក្នុងក្រុង ទីប្រជុំជន គឺ មានលក្ខណៈទំនើបប្រសើរហើយ។

ស្របពេលដែលស្តង់ដាររស់នៅរបស់មនុស្សខ្មែរកាន់តែប្រសើរឡើង ភាពអាត្មានិយមបានកើតឡើងដែរ ភាពក្រអឺតក្រទម និងការរស់នៅដោយផ្តាច់ពីសហគមន៍នៃទំនាក់ទំនងក៏មានកាន់តែច្រើនដែរ។ ម្នាក់ៗខិតខំ និងសង្វាតដណ្តើមយកធ្វើជារបស់ផ្ទាល់ខ្លួន សម្ភារៈនិយមកាន់តែខ្លាំង និងភាពបែងចែកក៏កាន់តែសំបូរបែបផងដែរ។ មនុស្សរាប់អានគ្នា ដោយបក្ស ដោយពួក ទាញប្រយោជន៍មិនចេះស្កប់ស្កល់ ប្រើខ្សែបណ្តោយជាប្រព័ន្ធ និងមិនសូវញញើតជាមួយច្បាប់ឡើយ។ ម្នាក់ៗទាញយកស្នាដៃរៀងៗខ្លួន មិនសូវខ្វល់ពីគុណតម្លៃរបស់មនុស្ស និងមិត្តភាពមានតែខាងក្រៅ។ ភាពកាចសាហាវ ភាពរឹករវ ការរំលោភបំពានទាំងរាងកាយ ចិត្ត និងទ្រព្យសម្បត្តិ ដីធ្លី ផ្ទះសំបែង។ ច្រណែនឈ្នានីស បំផ្លាញ បំភ្លៃការពិត មួលបង្កាច បោកបញ្ឆោត គឺកើតមានជាហូរហែរ។

ត្រង់នេះយើងត្រូវតែរិះគិត និងចាប់អារម្មណ៍ មិនអាចមើលរំលងបានទេ។ តើម្នាក់ៗត្រូវរៀបចំចិត្ត រៀបចំខ្លួនយ៉ាងដូចម្តេច? តើម្នាក់ៗបានសម្របខ្លួននឹងភាពរីកចម្រើន នៃប្រទេសកម្ពុជាហើយឬនៅ? យុវជន យុវសិស្សបានត្រៀមខ្លួនឬទេ? គ្រប់គ្នាបានបង្ហាញនូវបញ្ហាមួយចំនួនដែលខ្លួនបារម្ភ អំពីលំហូរនៃជនបរទេស ដែលមករកទទួលទាននៅកម្ពុជា ភាពអាណាធិបតេយ្យនៃជនបរទេសនៅកម្ពុជា សេវាសាធារណៈ មិនឆ្លើយតបបានសមស្រប សេវាសុខភាពនៅមានកម្រិត អ្នកមានធនធានចេញទៅព្យាបាលនៅបរទេស ព្រោះគ្មានទំនុកចិត្តជាដើម។ល។

គ្រប់គ្នាបានមើលឃើញនូវបញ្ហាយ៉ាងច្បាស់តាមពិសោធន៍របស់ខ្លួន។ សំណួរ ហេតុអ្វីតែងតែផុសចេញមកជានិច្ច។ ហេតុអ្វីការផ្តល់បណ្ណកម្មសិទ្ធិនៅយឺតយ៉ាវ នីតិវិធីថ្នាក់ក្រោមមានភាពស្មុគស្មាញ? ហេតុអ្វីទំនាស់ដីធ្លីនៅតែកើតមាន និងបន្តកើតមានការរំលោភដីគ្នាទៅវិញទៅមក។ ហេតុអ្វីសេវាសាធាណៈមានកម្រិត? មានជនឱកាសនិយមចូលជ្រែករហូតពេលណាទើបចប់? ហេតុអ្វី ហេតុអ្វី....?

ប៉ុន្តែតើគ្រប់គ្នាចេះស្វែងរកចម្លើយសម្រាប់សំណួររបស់ខ្លួនឬទេ? យើងខ្ញុំជឿថាប្រាកដជាមាន ពិតជាបានស្វែងរកចម្លើយរួចហើយ ក្នុងសំណួររបស់ខ្លួននោះ។

យើងខ្ញុំគ្រាន់តែជូនចំណុចមួយចំនួន ជាការបើកផ្លូវបន្តិច គឺថាប្រសិនបើវិនិយោគិនបរទេសមកកាន់តែច្រើន នោះការងារដែលនឹងផ្តល់ឲ្យយុវជនក្នុងស្រុកក៏កាន់តែច្រើន ការអភិវឌ្ឍប្រទេសក៏មានឱកាសច្រើនផងដែរ។ យុវជនមានបានគិតទេថា នឹងទាញចំណេញពីអ្នកជំនួញទាំងនោះយ៉ាងដូចម្តេច មិនលក់ផ្ទះឲ្យអ្នកចំណូលថ្មី ព្រោះតែតម្លៃខ្ពស់នោះទេ ត្រូវសួរខ្លួនឯង ថាបានពង្រឹងសមត្ថភាពហើយឬនៅ? ត្រូវស្វែងរកឱកាសចូលក្នុងបរិបទថ្មីនេះ បើមិនដូច្នេះទេ បរទេសគេប្រើបរទេសគ្នាគេហើយ ព្រោះយើងគ្មានជំនាញឆ្លើយតបតាមសេចក្តីត្រូវការរបស់គេ។ បើមានឱកាសខ្លះគួររៀនភាសា និងវប្បធម៌ថ្មីរបស់អ្នកវិនិយោគសម័យទំនើបនេះផងដែរ។

គំហុកនៃលំហូររបស់អ្នកជំនួញថ្មីពីចិនមិនមែនជាបញ្ហាទេ តែមានបញ្ហា បើយើងមិនចេះពីរបៀបទាញយកប្រយោជន៍ពីអ្នកវិនិយោគទាំងនោះ។ ទោះជាយ៉ាងណាក្តី យើងក៏ត្រូវការការគាំទ្រពីអាជ្ញាធរ ក្នុងការគ្រប់គ្រង ពង្រឹងច្បាប់ស្រុកទេស ដែលត្រូវតែកម្រិតកម្មករបុគ្គលិកបរទេសប៉ុន្មានសម្រាប់បម្រើការក្នុងក្រុមហ៊ុនមួយ ដើម្បីធានានិរន្តភាពការងាររបស់ប្រជាជនក្នុងស្រុក។ ទាំងនេះត្រូវបំពេញឲ្យគ្នាទៅវិញទៅមក រវាងពលរដ្ឋ និងរដ្ឋ។ ពលរដ្ឋត្រូវពង្រឹងសមត្ថភាពរបស់ខ្លួន ឯរដ្ឋត្រូវធានាទាំងធនធាន និង ផ្លូវច្បាប់ មិនមែនអ្នកវិនិយោគជាអ្នកបំពុលបរិយាកាសរបស់កម្ពុជានោះទេ។ រឿងធំបំផុតដែលត្រូវប្រយ័ត្ននោះគឺ ការគប់គិតជាប្រព័ន្ធ និងវប្បធម៌អន្តរាគមន៍ជាចាំបាច់ត្រូវលប់បំបាត់ជាបន្ទាន់។

សរុបមកវិញ គ្រប់គ្នាត្រូវភ្ញាក់ខ្លួនហើយ ទទួលស្គាល់ការពិតថា ពេលនេះកម្ពុជាកំពុងដើរមកដល់ចំណុចណាហើយ មិនត្រូវឈរស្រែក ឈរថា រិះគន់ផ្តាច់សង្ខារនោះទេ ចេញដំណើរ ចេញសកម្មភាព ពង្រឹងសមត្ថភាព ពង្រឹងស្មារតី ចូលរួមជាភ្នែកជាច្រមុះរបស់អាជ្ញាធរ រិះគន់ស្ថាបនា ជាពិសេស ត្រូវតែទាញយកឲ្យបានពីផលដែលអ្នកនិយោគជនជាតិចិនមកនៅកម្ពុជាជាចាំបាច់។ អាជ្ញាធរត្រូវតែធានាផ្លូវច្បាប់សម្រាប់អ្នកវិនិយោគ ឲ្យរកស៊ីត្រឹមត្រូវ ដោយគោរពច្បាប់កម្ពុជា និងធានាផ្លូវច្បាប់ឲ្យពលរដ្ឋរបស់ខ្លួនទទួលផលពិតប្រាកដ។ «ម្នាក់ៗត្រូវនិយាយតែសេចក្តីពិតទៅកាន់បងប្អូនឯទៀតៗ ដ្បិតយើងជាសរីរាង្គរបស់គ្នាទៅវិញទៅមក» (អភ ៤,២៥)។ ដើម្បីក្លាយជាសមាជិកម្នាក់ផ្សេងទៀត នោះគ្រីស្តទូតបានលើកទឹកចិត្តយ៉ាងជ្រាលជ្រៅ ឲ្យយើងលះបង់ចោលសេចក្តីភូតកុហក ហើយនិយាយការពិត៖ កាតព្វកិច្ចត្រូវការពារសេចក្តីពិត ហូរមកពីសេចក្តីត្រូវការ មិនមកពីការភូតកុហកគ្នាក្នុងការទំនាក់ទំនងនោះទេ។ សេចក្តីពិតត្រូវបានបង្ហាញនៅពេលយើងរួបរួមគ្នា៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.វ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# ភាពតានតឹងនៅលើពិភពលោកដែលយើងគួរដឹង!



លោក ដូណាល់ត្រាំ ប្រធានាធិបតីសហរដ្ឋអាមេរិក



លោក ស៊ី ជិនភីង ប្រធានាធិបតីសាធារណរដ្ឋប្រជាមានិតចិន



លោក វ៉្លាឌីមៀរ ពូទីន ប្រធានាធិបតីរុស្ស៊ី

ដោយ៖ អរិយបុត្រ

ភាពតានតឹងដែលកំពុងតែកើតឡើងនៅលើពិភពលោកនាពេលបច្ចុប្បន្ននេះ មានច្រើនហើយជាកម្រិតពិភពលោក គឺរួមមានសង្គ្រាមពាណិជ្ជកម្មដែលកំពុងតែបន្តរវាងអាមេរិក និងចិន ភាពតានតឹងនៅមជ្ឈឹមបូព៌ារវាងអាមេរិក និងអ៊ីរ៉ង់ និងភាពតានតឹងនៅទ្វីបអាមេរិកខាងត្បូង រវាងអាមេរិក និងប្រទេសវេណេហ្ស៊ុយអេឡា ក៏ដូចជារឿងវិបត្តិនៅអឺរ៉ុបក្រោយការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប។ល។ នៅក្នុងចំណោមរឿងក្តៅធំៗទាំងនេះ អាមេរិកត្រូវបានគេដឹងថា គឺជាកាត្តាលីករដឹកចម្បងលើកលែងតែរឿងវិបត្តិនៅអឺរ៉ុប។

នៅក្នុងអំឡុងពេលនេះអាមេរិកកំពុងតែជាប់ដៃនៅក្នុងសង្គ្រាមពាណិជ្ជកម្ម ជាមួយនឹងចិនដែលមកដល់ត្រឹមនេះ គឺនៅមិនទាន់ដឹងថា តើវានឹងបញ្ចប់នៅពេលណា ហើយនរណាជាអ្នកឈ្នះនៅឡើយទេ។

នៅក្នុងឋានៈជាមហាអំណាចទីមួយនៅលើលោកទាំងយោធា និងសេដ្ឋកិច្ច អាមេរិកជាធម្មតាមិនអាចនឹងឱបដៃឈរមើលឥទ្ធិពល និងឧត្តមភាពនៃប្រទេសផ្សេងនៅលើពិភពលោកនោះទេ ខណៈដែលក្តីរំពឹងរបស់អ្នកសេដ្ឋកិច្ចមួយចំនួនបានឲ្យដឹងថា ចិនអាចនឹងដណ្តើមឧត្តមភាពនេះនៅពេលអនាគត។

សង្គ្រាមពាណិជ្ជកម្មរវាងចិននិងអាមេរិកនេះ អាចជារូបភាពថ្មីមួយនៃការដណ្តើមឥទ្ធិពល និងបង្ហាញអំពីសក្តានុពលនៃអំណាច ក៏ដូចជាទីតាំងភូមិសាស្ត្រ ដោយរួមទាំងការតប្រណាំងនៃបច្ចេកវិទ្យាផងដែរ រវាងមហាអំណាចទាំងពីរ។

ក្រោយពេលដែលសង្គ្រាមលោកលើកទីពីរបានបញ្ចប់ ពិភពលោកត្រូវបានបែងចែកជាពីរប៉ូល គឺប៉ូលមូលធននិយម ដែលដឹកនាំដោយអាមេរិក និង ប៉ូល កុម្មុយនីស្ត ដែលដឹកនាំដោយអតីតសហភាពសូវៀត។ ការតប្រណាំងឥទ្ធិពល និងឧត្តមភាពរវាងប៉ូលទាំងពីរ នេះ គឺបានកើតមាននូវរូបភាពនៃសង្គ្រាមមួយ គឺសង្គ្រាមត្រជាក់អូសបន្លាយរាប់ឆ្នាំរហូតសហភាពសូវៀតបានដួលរលំ នៅដើមទស្សវត្សរ៍នៃឆ្នាំ១៩៩០។ សហភាពសូវៀតបានបាត់បង់តួនាទីរបស់ខ្លួន ហើយក៏ត្រូវបានបែកខ្ញែកជាប្រទេសជាច្រើន។ នេះគឺជារឿងរ៉ាវសម័យនោះ ដូច្នេះ សង្គ្រាមពាណិជ្ជកម្មរវាងចិន និងអាមេរិកដែលកើតមាននៅពេលនេះ ប្រហែលជាអាចនឹងវិវត្តទៅរកសភាពរុំារ៉ៃ និង អូសបន្លាយពេលដូចជាសង្គ្រាមត្រជាក់នេះដែរហើយមើលទៅ។

ក្រោមនយោបាយជាតិនិយមដែលដាក់ចេញដោយលោកប្រធានាធិបតីដូណាល់ត្រាំ«អាមេរិកទីមួយ» និង ក្រោយពេលដែលគំនិតផ្តួចផ្តើម «ផ្លូវមួយ និង ខ្សែក្រវ៉ាត់មួយ» ដែលដាក់ចេញដោយលោកប្រធានាធិបតីចិន ស៊ី ជិនភីង ហាក់នៅលើផ្លូវមួយឆ្ពោះទៅរកភាពជោគជ័យ ខណៈដែលប្រទេសមួយចំនួនគាំទ្រ សូម្បីតែប្រទេសខ្លះនៅក្នុងសហភាពអឺរ៉ុប ដែលគេដឹងថា គឺជាសម្ពន្ធមិត្តរបស់អាមេរិកនោះ។ ចិនកាន់តែទទួលឧត្តមភាពនៅលើទីតាំងយុទ្ធសាស្ត្រ នៃសេដ្ឋកិច្ចជាមួយអន្តរជាតិ ដូច្នេះចង់មិនចង់អាមេរិក ត្រូវតែធ្វើអ្វីម៉្យាង។

តាមទំនោរ ! អ្នកវិភាគមួយចំនួនអាចរិះគិតថា នេះគឺជានយោបាយបុគ្គលដែលកើតឡើងដោយ លោក ដូណាល់ ត្រាំ ប៉ុន្តែបើទោះបីជាគ្មានលោកត្រាំ វានៅតែអាចកើតឡើង គ្រាន់តែរូបភាពនៃការកើតឡើងនោះវាមិនដឹងជាលេចឡើងតាមរូបភាពណាតែប៉ុណ្ណោះ។

សព្វថ្ងៃនេះ អាមេរិកបានវាយលុកខ្លាំងទៅលើចិន តាមរយៈយុទ្ធសាស្ត្របង្កើនពន្ធលើទំនិញផលិតនៅក្នុងប្រទេសចិន ដើម្បីធ្វើយ៉ាងណា កាត់ផ្តាច់សក្តានុពលសេដ្ឋកិច្ចចិន ដែលកំពុងតែមានកំណើនកើនឡើងយ៉ាងខ្លាំងក្លា។ មកដល់ពេលនេះ អាមេរិកបានវាយលុកចិនផ្ទួនៗ លើបញ្ហាពន្ធ ដោយបានអនុម័តតម្លើងពន្ធដល់ជុំទី៣ ហើយកំពុងតែពិចារណាតម្លើងពន្ធដល់ជុំទី៤ ថែមទៀត។ មកដល់ខែ ឧសភា អាមេរិក បានវាយពន្ធលើទំនិញចិនដល់កម្រិតប្រមាណជា២០០ ពាន់លានដុល្លារ ហើយ ហើយក៏គ្រោងនឹងបង្កើនឲ្យដល់ ៣០០ពាន់លានដុល្លារ ប៉ុន្តែចិនហាក់នៅស្ងាក់ស្ទើរ នៅក្នុងការវាយបកភ្លាមៗ។ ក្រៅពីពន្ធនេះ អាមេរិកវាយលុកមួយទៀត គឺវាយបំបាក់ក្រុមហ៊ុនបច្ចេកវិទ្យាយក្សរបស់ចិន គឺ ក្រុមហ៊ុន ហួរវេ ក្រោមលេសថា ជាក្រុមហ៊ុនធ្វើចារកម្មឲ្យចិន។ នៅក្នុងសង្គ្រាមនេះ ចិន ក៏វាយលុកខ្លះដែរ ប៉ុន្តែហាក់មិនក្តៅខ្លាំងពេកទេ។ ហើយគេនៅមិនដឹងថា ទៅថ្ងៃមុខចិននឹងលេងហ្គេមនេះបន្តដោយវិធីយ៉ាងណាទៀតនៅឡើយទេ។ ចិនបានវាយបកពន្ធទៅលើផលិតផលអាមេរិកមួយចំនួន តែតុល្យភាពនៃការវាយបកនោះ គឺមិនទាន់សមតុល្យនឹងការវាយលុករបស់ចិននៅឡើយ ប៉ុន្តែសារមួយ កាលពីចុងខែ ឧសភា របស់លោក ស៊ីជិនភីង បានបង្ហាញថា ចិននឹងបន្តលេងហ្គេមនេះ គ្រាន់តែអាចដកឃ្លា និង អូសបន្លាយពេលវេលា ប៉ុន្តែនៅតែរក្សាជំហររឹងប៉ឹងនឹងហ្គេមសង្គ្រាមពាណិជ្ជកម្មនេះបន្ត។

ភាពតានតឹងមួយជ្រុង នៅមជ្ឈឹមបូព៌ាឯណោះវិញ អាមេរិកបើទោះបីជាកំពុងតែជាប់ផុងនៅក្នុងសង្គ្រាម នៅមជ្ឈឹមបូព៌ា ដូចជា អ៊ីរ៉ាក់ នៅស៊ីរី និងនៅអាហ្គានីស្ថាន ជាដើមនោះ ក៏កំពុងតែសង្កៀតធ្មេញបន្ថែមទៀតដាក់ អ៊ីរ៉ង់ ដោយនៅពេលនេះ បានប្រកាសដាក់ទណ្ឌកម្មអ៊ីរ៉ង់ និង បានបញ្ជូនកម្លាំង និងយោធូបករណ៍យោធាជាច្រើនទៅមជ្ឈឹមបូព៌ា។ គេនៅតែមិនដឹងថា តើអាមេរិក និង អ៊ីរ៉ង់ នឹងកើតសង្គ្រាមជាមួយគ្នាយ៉ាងណានោះទេ ប៉ុន្តែ នៅពេលនេះគេដឹងថា រុស្ស៊ី ដែលកំពុងតែមានវត្តមាននៅមជ្ឈឹមបូព៌ាស្រាប់ ជាពិសេសនៅ ស៊ីរី ប្រហែលជាមិនឱបដៃនៅក្នុងភាពតានតឹងនោះទេ។ វាមិនមែនជារឿងលេងសើចពេកនោះទេ ប្រសិនបើអាមេរិក ឬរដ្ឋបាលលោកដូណាល់ត្រាំ លេងល្បែងសង្គ្រាមជាមួយនឹងអ៊ីរ៉ង់នៅក្នុងពេលនេះ។ តួយ៉ាងនៅក្នុងការលុកលុយរបស់អាមេរិកចូលអ៊ីរ៉ាក់ គឺអាមេរិកចំណាយថវិកាជាតិដ៏មហាសាលនៅក្នុងប្រទេសនេះ។ តាមតួលេខដែលគេបានឲ្យដឹងនៅក្នុងចន្លោះឆ្នាំ ២០០៣ ដល់ ២០១០ អាមេរិកចំណាយថវិការជាង ១ ទ្រីលានដុល្លារ។ នេះ និយាយ អំពីនៅអ៊ីរ៉ាក់តែមួយទេ ចុះនៅការជាប់ផុងនៅក្នុងសង្គ្រាមនៅអាហ្គានីស្ថាន នៅស៊ីរី និង ប្រទេសមួយចំនួនទៀតនោះ។

នៅទ្វីបអាមេរិកខាងត្បូងឯណោះវិញ ក៏ជារឿងក្តៅមួយដែរ មកដល់ពេលនេះ អាមេរិក នៅតែចិញ្ចឹមចិត្តថា ផ្តួលមេដឹកនាំនៅក្នុងប្រទេសវេណេហ្ស៊ុយអេឡា ដែលកំពុងកាន់អំណាចដោយរាប់បញ្ចូលទាំងជម្រើសយោធា។ អាមេរិកបានគម្រាមថា គ្រប់ជម្រើសទាំងអស់ កំពុងតែស្ថិតនៅលើតុ ដើម្បីដោះស្រាយបញ្ហានៅក្នុងប្រទេសវេណេហ្ស៊ុយអេឡា ដែលជាប្រទេសក្បែរខាងខ្លួន និង នៅក្នុងតំបន់មួយ ខណៈដែលពេលនេះ គេដឹងថារុស្ស៊ី ដែលធ្លាប់បាត់បង់ ប៉ូល ឬ ទីតាំងភូមិសាស្ត្រនយោបាយមួយរបស់ខ្លួន នៅក្រោយពេលដែលសង្គ្រាមត្រជាក់ផ្តួលសហភាពសូវៀត នោះ កំពុងតែពង្រឹងជំហរ និងតួនាទីរបស់ខ្លួននៅទ្វីបនេះឡើងវិញនោះ។

ទាំងនេះគឺជារឿងក្តៅទាំងអស់ ដោយឡែកការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុបនៅពេលនេះ ក៏ជារឿងមន្ទិលមួយសម្រាប់ពិភពលោកផងដែរ។ រឿងនេះ គឺសុទ្ធតែជារឿងក្តៅ ហើយអ្នកជំនាញកំពុងតែតាមដាន។

សរុបមកវិញ រឿងក្តៅនៅលើពិភពលោកនៅពេលនេះ អាចមានប៉ុន្មានរឿងធំៗហ្នឹង ដូច្នេះយើងគួរតែតាមដាន ហើយរឿងនេះ ថ្វីត្បិតតែវាមិនពាក់ព័ន្ធនឹងយើងដោយផ្ទាល់ ប៉ុន្តែបើវាកើតឡើងមែននោះ យើងទាំងអស់គ្នាទោះបីជារស់នៅប្រទេសតូចតាច មិនសូវមានទំនាក់ទំនងដោយផ្ទាល់ក៏ពិតមែន ប៉ុន្តែផលប៉ះពាល់ នឹងកើតមាន ហើយឥទ្ធិពលអវិជ្ជមាននឹង ប្រឈមសម្រាប់យើងទាំងអស់គ្នា ជាមិនខាន ដូច្នេះការតាមដាន និង អាចឲ្យយើងមានដំណោះស្រាយ ឬក៏វិធានការនៅក្នុងការប្រឈមមុខ និង បញ្ចៀសនូវផលប៉ះពាល់ធ្ងន់ធ្ងរបាន៕



អាមេរិក និងប្រទេសអារ៉ាប៊ីសាអូឌីត ចោទអ៊ីរ៉ង់ជាអ្នកវាយប្រហារនាវាដឹកប្រេងក្នុងសមុទ្រអូម៉ង់កាលពីថ្ងៃទី១៣មិថុនា កន្លងទៅ ដែលនាំឱ្យស្ថានការណ៍កាន់តែតានតឹងបន្ថែមទៀត។ រូបភាព៖ AP



*ការចោលសំរាមពាសវាលពាសកាល និងមិនចោលក្នុងធុងសំរាមធ្វើឱ្យបរិស្ថានអាប់អួរ និងខ្វះសោភ័ណភាព។ រូបភាព៖ ស៊ីអេសស៊ី*

# សំរាមកំពុងក្លាយជាបញ្ហាក្តៅ សម្រាប់កម្ពុជា

*ដោយ៖ ផល សុផានិត*

ទឹកទន្លេត្រជាក់ ខ្យល់បក់រំភើយៗ រួមជាមួយសំឡេងអ៊ូអរបស់មនុស្សក្មេងចាស់ប្រុសស្រី នៅខាងមុខព្រះបរមរាជវាំង រាជធានីភ្នំពេញ ជាកន្លែងដែលប្រជាពលរដ្ឋ តែងមកកំសាន្តក្នុងពេលល្ងាច ជាពិសេសក្នុងពេលចុងសប្តាហ៍។

ជាមួយនឹងសំឡេងយានយន្តគ្រប់ប្រភេទ លាយឡំជាមួយនឹងផ្សែងពុលដែលបង្កឡើងដោយយានយន្តនិងការបោះចោលសំរាមបានធ្វើឱ្យកន្លែងកម្សាន្តដ៏ពេញនិយមនារាជធានីភ្នំពេញរាយប៉ាយ ដោយក្រដាស ថង់ប្លាស្ទិក និងសំណល់ចំណីអាហារនានា។ ការបំពុលបែបនេះ បាននឹងកំពុងធ្វើឱ្យបរិស្ថានកខ្វក់ជាខ្លាំង ជាពិសេសរាជធានីដែលជាបេះដូងនៃប្រទេស។

ក្រុងភ្នំពេញមួយថ្ងៃៗប្រជាពលរដ្ឋតែងតែមកកំសាន្តនៅទីនេះ និងតែងតែបោះចោលសំរាមបន្ទាប់ពីទទួលទានរួច ដូចជាសណ្តែកដី ដបទឹកសុទ្ធ និងរបស់របរជាច្រើនទៀត។

យុវជនម្នាក់មកពីខេត្តកំពង់ធំ ឈ្មោះ តុលា បាននិយាយថា រូបគាត់តែងតែប្រាប់ដល់អ្នកដទៃឱ្យបោះចោលសំរាមទៅក្នុងធុងសំរាម ហើយកុំចោលចំណីអាហាររបស់ពួកគេនៅការ៉ូឡា និងច្រាំងទន្លេ តែក្នុងចំណោមនោះអ្នកខ្លះក៏ស្តាប់ និងអ្នកខ្លះក៏ធ្វើមិនដឹង។ យ៉ាងណាក៏ដោយយុវជនរូបនេះបាននិយាយថា បើធៀបទៅនឹងបណ្តាឆ្នាំមុន សកម្មភាពនៃការបោះចោលសំរាម និងកាកសំណល់ផ្សេងៗបានថយចុះ ហើយបរិស្ថានមានភាពប្រសើរជាងមុន។

អ្នកលក់ភេសជ្ជៈ នៅខាងមុខព្រះបរមរាជវាំង អ្នកស្រី សុខ ឃីម បានយល់ឃើញថា សំរាមជាបញ្ហាដែលធ្វើឱ្យកខ្វក់ និងបញ្ហាទំលាប់របស់ប្រជាពលរដ្ឋមួយចំនួន មិនបានផ្លាស់ប្តូរទំលាប់ ដោយតែងតែទុកនៅសំរាម និងថង់ប្លាស្ទិករបស់ពួកគេចោល បន្ទាប់ពីពួកគេទទួលទាន។

ស្ត្រីរូបនេះ បន្តថា អ្នកស្រី តែងតែជួយរើសខ្ចប់ដបទឹកសុទ្ធ និងកំប៉ុងទឹកផ្លែឈើ ព្រោះអ្នកស្រីយល់ឃើញថា ទីក្រុងស្អាតមិនគួរបោះចោលសំរាមដូចនេះទេ។

អ្នកស្រី សុខ ឃីម និយាយថា «វាមិនល្អទេព្រោះប្រទេសយើងជាប្រទេសមួយដែរ បើបរទេសគេមើលមកក៏គេនិយាយដែរមិនមែនតែប្រទេសយើងមួយទេ បើសិនពួកខ្ញុំជាអ្នកលក់ជួយរើសទៅវាអាច ជួនអីពេលដែលខ្ញុំនិយាយទៅ បងៗញាំជួយយកទៅដាក់ក្នុងធុងសំរាមទៅកុំចោលចឹង»។

ក្នុងសំលៀកបំពាក់កីឡា លោក កូវ ឃុី បាននិយាយថា លោកតែងតែរត់ហាត់ប្រាណជារៀងរាល់សប្តាហ៍នៅខាងមុខព្រះបរមរាជវាំង។

បុរសវ័យ៥៥ឆ្នាំរូបនេះតែងយកចិត្តទុកដាក់ពីសុខភាពរបស់ខ្លួនហើយ លោកតែងមានអារម្មណ៍មិនល្អនៅពេលដែលលោកឃើញប្រជាពលរដ្ឋបោះចោលសំរាមរាយប៉ាយ ដោយលោកគិតថាវាប៉ះពាល់ដល់មុខមាត់ប្រទេសជាតិ និងទេសចរណ៍ផងដែរ។

លោកឃុី បានលើកឡើងពីផលវិបាកនៃការបោះចោលសំរាម និងឥរិយាបទរបស់ប្រជាពលរដ្ឋ គឺពិបាកក្នុងការអប់រំ តែវាទាមទារពេលវេលានិងគួរផាកពិន័យ ឱ្យបានធ្ងន់ធ្ងរ។

លោក កូវ ឃុី បាននិយាយថា៖ «បរិស្ថាននៅទីនេះ ឥលូវៗនេះវាល្អហើយ គ្រាន់តែខ្វះខាតតិចតួចទេ ប្រជាជនយើងហូបចុកគួរជួយដាក់ស្បោង ដាក់ចូលធុងសំរាមឱ្យបានត្រឹមត្រូវ»។

ក្រសួងបរិស្ថានបានឱ្យដឹងថា សំណល់រឹង និងសំរាមមានប្រមាណ ២ពាន់ ៧០០តោន ត្រូវបានបង្កើតឡើងក្នុងមួយថ្ងៃៗនៅរាជធានីភ្នំពេញ។ នេះបើតាមហ្វេសប៊ុករបស់ក្រសួងបរិស្ថាន កាលពីខែកញ្ញា ២០១៨កន្លងទៅ។

តាមមន្ត្រីនាំពាក្យក្រសួងបរិស្ថាន លោកនេត្រ ភក្ត្រាឲ្យដឹងថា កំណើនសំរាមនៅរាជធានីភ្នំពេញនៅពេលនេះ គឺដោយសារតែកំណើនប្រជាពលរដ្ឋ ការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងទំនៀមទម្លាប់នៃការប្រើប្រាស់ និងការវេចខ្ចប់ទំនិញ ហើយការកែច្នៃពីសំរាមនៅមានកម្រិតទាបនៅឡើយ៕







# អាជីវករនិងអ្នកប្រើប្រាស់ទូរសព្ទ Huawei នៅកម្ពុជាមិនសូវចាប់អារម្មណ៍និងជម្លោះអាមេរិក-ចិន

*ដោយ៖ អរិយ្យបុត្រ*

ថ្មីៗនេះ ចលាចលមួយបានកើតឡើងក្នុងពិភពលោកដោយសារតែការដាក់បំរាមរបស់សហរដ្ឋអាមេរិកលើក្រុមហ៊ុនទូរសព្ទដៃទំនើបលំដាប់ពិភពលោកមួយរបស់ចិន ឈ្មោះ ហួវ៉េ (Huawei)។ ក្រុមហ៊ុននៅក្នុងសហរដ្ឋអាមេរិកដែលពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនទូរសព្ទមួយនេះ បានប្រកាសជាបន្តបន្ទាប់ ផ្តាច់ការផ្គត់ផ្គង់លើHardware និង Software ដល់ក្រុមហ៊ុនហួវ៉េ។ ហើយបណ្តាប្រទេសមួយចំនួនដែលជាសម្ពន្ធមិត្តរបស់អាមេរិកក៏បានដាក់បម្រាមមិនឲ្យប្រើប្រាស់ទូរសព្ទម៉ាកហួវ៉េផងដែរ។





*ក្រុមហ៊ុនបច្ចេកវិទ្យា Google បានប្រកាសនឹងបញ្ឈប់សេវាកម្មបច្ចេកវិទ្យាដល់ក្រុមហ៊ុនទូរស័ព្ទដៃទំនើបលំដាប់ពិភពលោក Huawei។ រូបភាព៖ Google*



*អតិថិជនពិនិត្យផលិតផលទូរស័ព្ទ Huawei ។ រូបភាព៖ សហការី*

នៅក្នុងប្រទេសកម្ពុជាទូរសព្ទទំនើបម៉ាកហួវ៉េនៅតែបន្តលក់ជាធម្មតានៅតាមហាងទូរសព្ទនានា។ ប៉ុន្តែអ្នកប្រើប្រាស់ និងអាជីវករមួយចំនួនកំពុងសម្តែងការព្រួយបារម្ភទាក់ទិននឹងជម្លោះនៃបច្ចេកវិទ្យាទូរសព្ទរបស់ប្រទេសមហាយក្សទាំងពីរនេះដែរ។

កញ្ញាស៊ិន ស៊ីវអេង ជាម្ចាស់ហាងលក់ទូរសព្ទដៃទំនើប ឃីហោ ស៊ីវអេង ឲ្យដឹងថា បើប្រកាសរបស់អាមេរិកជាការពិតមែននោះ ទូរសព្ទដៃរបស់ចិននឹងគ្មានន័យឡើយ បើទោះបីចិនវិវត្តបច្ចេកវិទ្យារបស់ខ្លួនពិតមែន តែអ្នកប្រើប្រាស់បានស៊ាំនឹងបច្ចេកវិទ្យាដែលផ្តល់ដោយអាមេរិកទៅហើយ។

កញ្ញា ស៊ិន ស៊ីវអេង បន្ថែមថា បច្ចុប្បន្នហាងរបស់នាង បានផ្អាកទិញទូរសព្ទដៃ ដែលផលិតនៅប្រទេសចិនមួយចំនួន ព្រោះកត្តាតំលៃនៅតែជារឿងសំខាន់ណាស់ សម្រាប់ការជ្រើសរើសរបស់អតិថិជនរបស់នាង។

កញ្ញា ស៊ិន ស៊ីវអេង និយាយថា កាលពីសម័យមុនអតិថិជនទិញទូរសព្ទសម្រាប់តែហៅចេញ និងហៅចូលតែប៉ុណ្ណោះ។ ប៉ុន្តែមកដល់ពេលនេះ ពួកគាត់រកតែទូរសព្ទដែលអាចប្រើអ៊ីនធឺណិត ដើម្បីចូលមើលយូធូប និងចូលទៅបណ្តាញទំនាក់ទំនងសង្គម (Social Media) ផ្សេងៗ។

ស៊ីវអេង៖ «អាចនិយាយបានថា យើងប្រើស៊្ទីក៏បានដែរនៅលើទូរសព្ទយើងតែមួយនេះ ព្រោះថាសម័យនេះជាសម័យស្មាតហ្វូន»។

នៅក្នុងប្រទេសកម្ពុជាទិន្នន័យក្នុងខែមករាឆ្នាំ២០១៩ របស់ក្រុមហ៊ុន Hootsuite ដែលសិក្សាអំពីប្រព័ន្ធឌីជីថលបានឲ្យដឹងថា ក្នុងចំណោមប្រជាពលរដ្ឋជាង១៦លាននាក់ មានអ្នកប្រើប្រាស់ទូរសព្ទចំនួនជាង២៥លានគ្រឿង ដែលក្នុងនោះមានអ្នកប្រើប្រាស់បណ្តាញសង្គមនៅលើស្មាតហ្វូនមានចំនួនជាង៨លានគ្រឿង។

លោក បញ្ញា ដែលអះអាងថា ជានិស្សិតឆ្នាំទី៣ កំពុងរកមើលទូរសព្ទដៃក្នុងហាងលក់ទូរសព្ទមួយកន្លែងក្នុងរាជធានីភ្នំពេញ បាននិយាយថា «ខ្ញុំមិនមានការព្រួយបារម្ភណ៍នោះទេ ចំពោះជម្លោះពាណិជ្ជកម្មរបស់ចិន និងសហរដ្ឋអាមេរិកនោះ ព្រោះនៅតែមិនជឿនោះទេ»។ លោកបានអះអាងទៀតថា៖ «នេះគ្រាន់តែការធ្វើពាណិជ្ជកម្មរបស់គេ (ចិន និងអាមេរិក) តែប៉ុណ្ណោះ។ បើទោះជាការពិតមែន ក៏ចិនដែលបច្ចុប្បន្ននេះជាមហាអំណាចមួយដែរក្នុងពិភពលោកនឹងមិនឈរឱបដៃមើលដែរ»។





*ផលិតផលទូរស័ព្ទ Huawei ដែលមានដាក់តាំងលក់នៅក្នុងរាជធានីភ្នំពេញ ។ រូបភាព៖ សហការី*

ចំណែក អ្នកលក់ទូរសព្ទដៃទំនើប ក្នុងហាង វុឌ្ឍី នៅបណ្តោយមហាវិថីព្រះមុនីវង្ស គឺលោក មិថុនា បាននិយាយថា ការប្រមូលទិញមកវិញពីក្រុមហ៊ុនហួវ៉េនោះ គឺគ្រាន់តែជាពាក្យដែលមនុស្សនិយាយតគ្នាតែប៉ុណ្ណោះ។ មកដល់ពេលនេះ លោកមិនបានឃើញភ្នាក់ងារក្រុមហ៊ុនទូរសព្ទមួយនេះមកប្រមូលទំនិញវិញនោះឡើយ។

លោកមិថុនា ឲ្យដឹងថា៖ «ពាក្យចចាមអារាមតែប៉ុណ្ណោះ។ ហាងខ្ញុំនៅលក់ធម្មតានៅម៉ូឌែលនេះ តែគ្រាន់តែឥលូវមនុស្សទិញម៉ូតនេះរៀងតិចជាងមុន។ ខ្ញុំនៅតែបញ្ជាទិញពីក្រុមហ៊ុនដើម្បីលក់ធម្មតាហ្នឹង»។

លោក មិថុនា យល់ឃើញថា ទោះបីជាមានការប៉ះទង្គិចរវាងចិន និងអាមេរិកលើបច្ចេកវិទ្យាទូរសព្ទក៏ដោយ ក៏បញ្ហានេះ ហាក់មិនផ្តល់ផលប៉ះពាល់ដល់អ្នកប្រកបអាជីវកម្មក្នុងប្រទេសកម្ពុជាលើវិស័យនេះដែរ។ លោកមិថុនា៖ «វាក៏គ្មានប៉ះពាល់អីដល់អាជីវកម្មនៅក្នុងស្រុកយើងដែរ ព្រោះអ្នកលក់ក្នុងស្រុកយើង នាំចូលមកច្រើនម៉ូត ច្រើនម៉ាកណាស់ មិនសំដៅតែមួយៗដូចប្រទេសគេនោះទេ»។

សហរដ្ឋអាមេរិកបានចោទប្រកាន់ក្រុមហ៊ុនទូរសព្ទម៉ាកហួវ៉េថាបានលួចទិន្នន័យ និងជាចារកិច្ចរបស់ប្រទេសចិន។

ប៉ុន្មានថ្ងៃមុននេះ ប្រទេសក្នុងតំបន់អាស៊ាន ដូចជាប្រទេស សិង្ហបុរី និងប្រទេសហ្វីលីពីនបានប្រកាសផ្អាកការនាំចូលនៅទូរសព្ទដៃម៉ាក ហួវ៉េ របស់ប្រទេសចិន ដោយខ្លាចបំរាមសហរដ្ឋអាមេរិកក្លាយជាការពិត។ ហើយក៏មានប្រទេសមួយចំនួន និងអ្នកប្រើប្រាស់បារម្ភណ៍ពីបញ្ហានេះដែរ បើទោះបីជាក្រុមហ៊ុន ហួវ៉េ ប្រកាសតបតវិញដោយបង្កើតបច្ចេកវិទ្យាខ្លួនឯងយ៉ាងណាក៏ដោយ។

កាលពីពាក់កណ្តាលខែឧសភានេះ ក្រុមហ៊ុនបច្ចេកវិទ្យារបស់ហ្គោហ្គល (Google) បានប្រកាសខ្លួននឹងបញ្ឈប់សេវាកម្មបច្ចេកវិទ្យាដល់ក្រុមហ៊ុនមួយនេះ។ មានន័យថា អ្នកដែលប្រើប្រាស់ទូរសព្ទម៉ាកហួវ៉េ មិនអាចចូលទៅក្នុងប្រព័ន្ធអេនដ្រយ (Android), Gmail, Youtube, Google drive, រួមនឹងកម្មវិធីផ្សេងទៀតរបស់ហ្គោហ្គល។ ហើយក្រុមហ៊ុនមួយចំនួនទៀតក៏ប្រកាសមិនលក់បន្ទះឈីប និង Hardware ផ្សេងទៀតដល់ក្រុមហ៊ុននេះដែរ៕



# កុំទម្លាប់ និយាយបង្អាប់ ឬ ចំអន់ចិត្តកូនក្មេង

មនុស្សចាស់មួយចំនួនធំចូលចិត្តនិយាយបង្អាប់ឬចំអន់ចិត្តកូនក្មេងនៅពេលដែលដឹងថា កុមារនោះនឹងមានប្អូនបន្ទាប់ម្នាក់ទៀត។ ឧទាហរណ៍៖ ប៉ាម៉ាក់នឹងលែងស្រលាញ់ទៀតហើយ ព្រោះមានប្អូនម្នាក់ទៀត ឬប៉ាម៉ាក់នឹងទុកចោលលែងរវល់ទៀតហើយ និងលែងស្រលាញ់ទៀតជាដើម។ សម្ដីនេះជាពាក្យលេងសើចដោយក្ដីស្រលាញ់ចំពោះកូនក្មេងតូច ៗ ប៉ុន្ដែវាបានប៉ះពាល់អារម្មណ៍ពួកគេយ៉ាងខ្លាំង គឺធ្វើឱ្យគេមានគំនុំ ហើយស្អប់ប្អូនក្រោយដោយសារខ្លាចប៉ាម៉ាក់លែងស្រលាញ់ដូចអ្វីដែលពួកគេបានឮ ព្រោះគេមិនទាន់ចេះបែងចែកច្បាស់អំពីសម្ដីលេងសើចឬមែនទែននោះទេ។

*ដោយ៖ រឿន ស្រីម៉ាច*

«មិនហ៊ានទុកកូនតូចឱ្យនៅតែពីរនាក់បងគេទេ ព្រោះអាបងនឹងធ្វើបាបអាប្អូនដូចជាវាយ ឬដាក់ខ្នើយខ្ទប់មុខជាដើម»។ នេះជាសម្ដីរបស់អ្នកស្រី ភិន សុភី វ័យ ៣៥ឆ្នាំ ជាស្ដ្រីមេផ្ទះនៅភ្នំពេញ។

ស្ដ្រីរូបនេះតែងតែជួបហេតុការណ៍បែបនេះជាញឹកញាប់បន្ទាប់ពីកូនប្រុសក្រោយរបស់អ្នកស្រីកើតមក។ អ្នកស្រីបានឲ្យដឹងថា ពេលដែលប្អូននៅក្នុងផ្ទៃ កូនបងហាក់ដូចជាស្រលាញ់ប្អូនខ្លាំង គឺតែងតែនិយាយលេងជាមួយ ឬឱបថើបពោះជាដើម តែនៅពេលដែលប្អូនកើតចេញមក គឺមិនបានប៉ុន្មានគាត់បែរជាមិនចូលចិត្តប្អូនទៅវិញ។ អ្នកស្រីពោលថា គឺភាគតិចណាស់ដែលគេស្រលាញ់ប្អូន។

ស្ដ្រីរូបនេះបន្ថែមថា៖ «អ្វីដែលធ្វើឱ្យកូនអ្នកស្រីក្លាយជាក្មេងមិនល្អបែបនេះគឺមកពីអ្នកជិតខាងឬយាយតា ពូមីងតែងតែនិយាយចំអន់ថា នឹងលែងមានអ្នកស្រលាញ់គេទៀត ព្រោះគេមានប្អូនក្រោយហើយ។ ពាក្យនេះពេលខ្លះធ្វើឱ្យកូនប្រុសច្បងខ្ញុំយំ ឬមិនសប្បាយចិត្តជាដើម បើទោះបីខ្ញុំជាម្ដាយឪពុកព្យាយាមនិយាយលួងលោមគេបែបណាក៏ដោយ ព្រោះអ្វីដែលចំអន់នោះនៅជាប់ក្នុងចិត្តគេជានិច្ច»។

ចំណែកអ្នកស្រី ញឹប យឿន វ័យ ២៩ឆ្នាំ ជាអាជីវករលក់ដូរនៅក្នុងផ្សារបឹងទំពុនបានឱ្យដឹងផងដែរថា៖ «ពេលខ្លះអ្នកស្រីខឹងអ្នកដែលតែងតែនិយាយបង្អាប់កូនរបស់ខ្លួនថា គាត់នឹងលែងស្រលាញ់គេដូចមុន ព្រោះតែមានប្អូនក្រោយ។ សម្ដីនេះវាជាការលែងសើចតែកូនរបស់អ្នកស្រីបានផ្លាស់ប្ដូរចរិតក្រោយពេលដែលបានស្ដាប់ពាក្យទាំងនោះ»។

តាមរយៈបទពិសោធនេះ ធ្វើឲ្យអ្នកស្រីឈ្វេងយល់ថា ការវិវឌ្ឍចិត្តសាស្ដ្ររបស់កុមារតូច គឺត្រូវការមនុស្សចាស់ និយាយដោយត្រង់ ព្រោះពួកគាត់មិនទាន់ចេះបែងចែកអ្វីដែលហៅថានិយាយលេងសើចនោះឡើយ។ ការបន្ទោស ឬបង្អាប់ ប្រៀបធៀបរវាងបងប្អូន គឺនាំឲ្យកុមារមានភាពច្រណែនដោយមិនដឹងខ្លួន ហើយភាពស្អប់ក៏កើតចេញមក។

អ្នកស្រី យឿន មានប្រសាសន៍ថា៖ «ដូចជាកូនខ្ញុំ គេនិយាយបង្អាប់យូរៗ ឥឡូវចេះនិយាយសម្ដីថា ពេលប្អូនកើតមក នឹងយកទៅបោះចោលជាដើម។ នេះវាប៉ះពាល់ផ្លូវចិត្តក្មេងច្បាស់ណាស់»។

លោក ប៊ុន ថារ៉ូ វ័យ ៤២ឆ្នាំ ជាប្រធានក្រុមហ៊ុនមួយកន្លែងក្នុងទីក្រុងភ្នំពេញបានឱ្យដឹងផងដែរថា៖ «ខ្ញុំតែងតែស្ដីបន្ទោសទៅអ្នកដែលចូលចិត្តនិយាយចំអន់ថា ខ្ញុំលែងស្រលាញ់កូនបងអីចឹងទៅ ព្រោះភាសានេះធ្វើឱ្យក្មេងបាក់ទឹកចិត្តឬមានចិត្តស្អប់ឪពុកម្ដាយ និងប្អូនៗគេជាដើម។ បើទោះបីគេនិយាយក្នុងន័យលេងសើចក៏មិនត្រូវនិយាយដែរ»។

ដោយភាពតឹងរឹងចំពោះការប្រើប្រាស់ពាក្យសម្ដីនេះ បានធ្វើឲ្យកូនរបស់លោកថារ៉ូ ចេះស្រលាញ់ប្អូនរបស់ខ្លួន។ លោកបានឲ្យដឹងថា ពាក្យមួយចំនួន ឪពុកម្ដាយ និងអ្នកជិតខាងគួរតែប្រើដើម្បីលើកទឹកចិត្តកុមារ កុំឲ្យពួកគេមានការភ័យខ្លាច និងចេះស្រលាញ់ដោយអស់ពីចិត្ត។

> ការធំធាត់ក្នុងគ្រួសារកក់ក្ដៅ និងយល់ពីតម្លៃជីវិត ជាផ្លូវត្រួសត្រាយបើកចិត្តឲ្យក្មេងសម្លឹងមើលអ្វី ៗក្នុងផ្លូវល្អជានិច្ច

លោកថារ៉ូ៖ «ប៉ាម៉ាក់ស្រលាញ់កូន! នេះជាពាក្យដែលខ្ញុំ និងភរិយាតែងនិយាយទៅកាន់កូនជារៀងរាល់ថ្ងៃ ហើយកូនតែងតែញញឹមត្រឡប់មកវិញ។ ហេតុនេះទាំងអ្នកនៅក្នុងផ្ទះជាមួយគ្នា ទាំងចាស់ទុំនៅខាងក្រៅគួរតែកុំនិយាយអ្វីដែលនាំឱ្យកូនក្មេងមិនសប្បាយចិត្ត ឬអន់ចិត្តដោយសារតែខ្លាចលែងមានអ្នកស្រលាញ់គេ។ គួរតែនិយាយអប់រំ និងប្រើកាយវិការល្អៗដើម្បីជាគំរូដល់កូនក្មេង ទើបល្អជាងការបង្អាប់កូនក្មេង»។

តាមប្រសាសន៍របស់លោក អ៊ុំ ផ្កាក ទីន ផ្នែកចិត្តសាស្ដ្រឯករាជ្យបានឱ្យដឹងថា ក្មេងតូចត្រូវការក្ដីស្រលាញ់ ការថ្នាក់ថ្នមពីសំណាក់ឪពុកម្ដាយ និងអ្នកនៅជុំវិញខ្លួន ដូចជា ផ្ដល់ចំណីអាហារ ផ្ដល់កន្លែងស្នាក់នៅ បញ្ជូនទៅសាលារៀន និងផ្ដល់នូវការអប់រំល្អៗដល់គេជាដើម។ ក្នុងនោះទង្វើមួយចំនួនដែលមិនគួរប្រព្រឹត្តមកលើកុមារដូចជា ស្ដីបន្ទោស ឬបន្ទុះបង្អាប់ ព្រោះកុមារអាចកាន់តែតូចចិត្ត ហើយប៉ះពាល់ផ្លូវអារម្មណ៍កាន់តែខ្លាំង។

លោកផ្កាកទីនបន្ថែមថា៖ «ឪពុកម្ដាយ ឬមនុស្សធំដឹងក្ដី ត្រូវបង្រៀន ត្រូវឲ្យក្មេងយល់ថា គេមានតម្លៃ និងមានភាពកក់ក្ដៅក្នុងគ្រួសារ។ ការធំធាត់ក្នុងគ្រួសារកក់ក្ដៅ និងយល់ពីតម្លៃជីវិត ជាផ្លូវត្រួសត្រាយបើកចិត្តឲ្យក្មេងសម្លឹងមើលអ្វីៗក្នុងផ្លូវល្អជានិច្ច»។

អ្នកចិត្តសាស្ដ្ររូបនេះ បន្តទៀតថា៖ «មិនត្រូវប្រើសម្ដីលេងសើច ឬទង្វើណាដែលនាំឱ្យក្មេងមានអារម្មណ៍តានតឹងក្នុងចិត្ត ឬភ័យខ្លាចបាត់បង់អ្វីមួយនោះទេ ជាពិសេសសេចក្ដីស្រលាញ់ពីឪពុកម្ដាយរបស់គេតែម្ដង»។







# ប្រជាជនចាត់ទុក សាលាវត្តបូព៌ ជាសាលាគំរូមួយប្រចាំប្រទេស



នៅពេលដែលយើងឮដល់ឈ្មោះសាលាបឋមសិក្សាវត្តបូព៌ គេស្គាល់ភ្លាមថា ជាសាលារៀនគំរូមួយប្រចាំប្រទេសកម្ពុជា។ សាលាបឋមសិក្សាវត្តបូព៌ មិនត្រឹមតែល្បីរន្ទឺទូទាំងប្រទេសនោះទេ ថែមទាំងល្បីដល់ក្រៅប្រទេសថែមទៀតផង។ តើកត្តាអ្វីខ្លះដែលធ្វើឱ្យសាលាបឋមសិក្សាវត្តបូព៌ ក្លាយជាសាលារៀនគំរូ និងល្បីឈ្មោះយ៉ាងដូច្នេះ?

*ដោយ៖ ផល សុផានិត*

សាលាវត្តបូព៌បានកកើតឡើងជាច្រើនឆ្នាំមកហើយ ហើយបានក្លាយជាសាលាគំរូមួយក្នុងប្រទេសដោយសារតែគុណភាពអប់រំខ្ពស់ និងមានវិន័យតឹងរឹង។ ហើយកុមារដែលបញ្ចប់ការសិក្សានៅសាលានេះ មានសុជីវធម៌និងសមត្ថភាពខ្ពស់។

នាយកសាលា លោក ពឹង គិមឆេង និយាយថា «អ្វីដែលធ្វើឱ្យមាតាបិតាសិស្ស ព្រមទាំងស្ថាប័ននានា ទទួលស្គាល់នោះ អ្វីដែលសំខាន់គឺ៣ចំណុចដែលជាចក្ខុវិស័យរបស់យើងខ្ញុំនេះឯង ទី១ គុណភាពនៃការអប់រំប្រកបដោយប្រសិទ្ធភាព ទី២ គឺយើងបានថែទាំសុខភាពកូនៗរបស់យើង ឱ្យបានកាន់តែល្អផ្នែកអនាម័យ ទី៣ ឥរិយាបថរបស់ពួកគេ ដែលមានសីលធម៌ សុជីវធម៌។ ទាំងអស់នេះ បើយើងនិយាយក្ដោបមក គឺមានតែ២ទេ គឺទី១វិន័យ និងសណ្ដាប់ធ្នាប់ ទី២ គឺគុណភាពនៃការរៀនរបស់ពួកគាត់»។

វិន័យ និងការអប់រំស្ដង់ដារ គឺជាអ្វីដែលគេនិយាយពីស្តង់ដាររបស់សាលាបឋមសិក្សាវត្តបូព៌។ វិន័យគឺនាំមកនូវសេចក្ដីថ្លៃថ្នូរ គណៈគ្រប់គ្រងរបស់សាលាមួយនេះបន្ថែមថា៖ «វិន័យដាក់ចេញជាគោលការណ៍មានលក្ខណៈ៥យ៉ាងគឺទី១ អប់រំពួកគេឱ្យចេះស្អាត ទី២ គឺអប់រំពួកគេឱ្យមានរបៀប ទី៣ គឺអប់រំពួកគាត់ឱ្យក្លាយទៅជាមនុស្សសុភាពរាបសារ ចេះឱនលំទោន ចេះគោរពចាស់ទុំ ចេះនិយាយស្ដីដោយពាក្យសមសួនវិន័យ អនុវត្តន៍ទៅលើការអនុវត្តម៉ោងពេល ទី៥ គឺឱ្យពួកគេរៀនធ្វើសមាធិ ដែលជាលក្ខណៈចាប់ផ្ដើមនៃការប្រមូលផ្ដុំនូវចំណុច៤ខាងដើម»។

ក្រៅពីការរឹតបន្ដឹងលើវិន័យ ការសិក្សាអប់រំ ចំណុចពិសេសដែលគួរឱ្យចាប់អារម្មណ៍លើសាលាបឋមសិក្សាវត្តបូព៌នេះគឺ លោកនាយកបានរៀបចំឯកសណ្ឋានឱ្យសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ នៅក្នុងគោលបំណង បង្កើតនូវសមធម៌ និងបំបាត់ការរើសអើង រវាងអ្នកមាន និងអ្នកក្រ។ លោកនាយកបន្តថា ឪពុកម្ដាយគ្រប់លំដាប់ថ្នាក់អាចយកកូនមករៀនបានទាំងអស់គ្នា មិនថា អ្នកមានឬអ្នកក្រនោះទេ។



*សិស្សានុសិស្សសាលាវត្តបូព៌។ រូបភាព៖ សហការី*

សាលារៀនវត្តបូព៌ជាសាលាស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋ ស្ថិតនៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប។ ក្រសួងអប់រំបានចាត់ទុកសាលាមួយនេះ ជាសាលាជំនាន់ថ្មីដែលជាសាលាគំរូប្រចាំប្រទេសកម្ពុជាក្នុងការអប់រំកុមារតូចៗ។

អាណាព្យាបាល និងឪពុកម្ដាយសិស្សជាច្រើនបានកោតសរសើរចំពោះវិន័យ និងការអប់រំរបស់សាលានេះ ចំពោះកូនៗរបស់គាត់។

អ្នកស្រី ង៉ែត សុជាតា៖ «សាលានេះជាសាលាល្អលេខមួយ ព្រោះកូនខ្ញុំរៀននៅទីនេះជាគ្រឹះរឹងមាំតែម្ដង ហើយកូនខ្ញុំរៀនពូកែណាស់ វិន័យ និងសីលធម៌ល្អ»។

រីឯអ្នកនាង សុជាតា ជាម្ដាយម្នាក់ទៀតបានឲ្យដឹងថា «តាំងពីកូនខ្ញុំមករៀននៅសាលានេះ មិនដែលឃើញសាលាណាល្អដូចនេះអីចឹងនោះទេ ទើបពេលដែលគាត់គ្រប់អាយុទើបយកមកដាក់សាលារៀននេះ ព្រោះសាលានេះវិន័យតឹងតែងល្អ ទាំងការស្លៀកពាក់ ការរស់នៅប្រចាំថ្ងៃ គឺគាត់បង្រៀនកូនយើងសព្វគ្រប់ចឹងទៅណា»។

កុមារី នារី សុធីតា រៀនថ្នាក់ទី ៥ក បាននិយាយថា៖ «ការធ្វើលំហាត់ ការសិក្សាទៅមុខ លោកគ្រូអ្នកគ្រូ តឹងរឹងក្នុងការសិក្សា ដែលធ្វើឱ្យខ្ញុំរៀនបានកាន់តែពូកែ ធ្វើលំហាត់លឿន និងមានវិន័យក្នុងការរស់នៅ»។

ចំណែកកុមារា រុន ដារីន ជាសិស្សថ្នាក់ទី៤ខ បានឲ្យដឹងដែរថា គាត់មានជំនាញគិតលេខកាន់តែលឿនជាងមុន ការសរសេរអក្សរ ការលេងកីឡា ការសមាធិ ធ្វើឲ្យពួកគាត់មានវិន័យច្រើនជាងក្មេងៗដទៃ ព្រោះសាលានេះគ្រូតឹងតែងខ្លាំងជាងសាលាដទៃទៀត។

សាលាបឋមសិក្សាវត្តបូព៌ បង្កើតឡើងតាំងពីឆ្នាំ១៩៥៧ លើផ្ទៃដី ១៣៧០២,៦៥ ម៉ែត្រក្រឡា។ សាលាបឋមសិក្សាមួយនេះពីដើមឡើយមានតែអាគារសិក្សាត្រឹមតែ ៣ប៉ុណ្ណោះ តែសព្វថ្ងៃមានរហូតដល់ ១៥អាគារសិក្សា ដែលមានប្រមាណ៦១បន្ទប់ និងចែកចេញជា២ផ្នែក គឺមត្តេយ្យសិក្សា និងបឋមសិក្សា ក្រោមការគាំទ្រពីសហគមន៍ក្នុងតំបន់ដែលមានមាតាបិតា សិស្ស និងអាណាព្យាបាល បានធ្វើឱ្យស្ថាប័នអប់រំមួយនេះទទួលបាននូវភាពជោគជ័យ លើគុណភាពអប់រំវិន័យសីលធម៌ និងបំណិននៃការសិក្សារៀនសូត្រ ដែលកំពុងផ្សាភ្ជាប់ជាមួយតថភាពសង្គមបច្ចុប្បន្ន៕



*លោក ពឹង គិមឆេង (ខាងស្ដាំ) នាយកសាលាវត្តបូព៌។ រូបភាព៖ សហការី*

# វាចាអ្នកម្ដាយចំពោះ គោលការណ៍ឧបត្ថម្ភថ្មីពីរដ្ឋ

ថ្មីៗនេះ រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយថ្មីមួយទៀត ដើម្បីលើកកម្ពស់សុខភាព មាតា និងទារក ឲ្យកាន់តែប្រសើរដោយមានប្រាក់ឧបត្ថម្ភនានាក្នុងអំឡុងពេលពពោះ សម្រាល និងក្រោយពេលសម្រាលកូន។ អ្នកម្ដាយទាំងឡាយដែលបានឮដំណឹងនេះមានសេចក្ដីរីករាយយ៉ាងខ្លាំង និងគាំទ្រចំពោះគោលការណ៍មួយនេះ។



*ដោយៈ ផល សុផានិត*

នៅពេលសួរថា តើអ្នកស្រី មានដឹងទេថា ចាប់ពីដើមខែមិថុនាស្ត្រីមានផ្ទៃពោះ នឹងទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ពីរដ្ឋាភិបាល?

កម្មការិនីរោងចក្រវ័យជាង២៨ឆ្នាំ អ្នកនាង សុជា ផល្លីន បាននិយាយថា ខ្លួនមិនបានដឹងពីព័ត៌មានពិតប្រាកដនោះទេ គ្រាន់តែឮអ្នករួមការងារប្រាប់ពីអ្វីដែលអ្នកស្រីនឹងទទួលបាននៅក្នុងរយៈពេល១ខែខាងមុខ។

អ្នកនាង សុជា ផល្លីន បានបន្តថា៖ «ដោយសារតែខ្ញុំរវល់តែធ្វើការងារនៅរោងចក្រទើបមិនសូវបានចាប់អារម្មណ៍រឿងនេះ»។

អ្នកស្រី បានបន្ថែមទៀតថា បើមានប្រាក់ឧបត្ថម្ភពីរដ្ឋមែន ពិតជាប្រសើរណាស់ ព្រោះអ្នកស្រីកំពុងពពោះជិតគ្រប់ខែទៅហើយ។

អ្នកស្រី ផល្លីន៖ «ចាស! គាត់ (រាជរដ្ឋាភិបាល) ធ្វើបែបនេះ គឺគាត់មានការយកចិត្តទុកដាក់ទាំងម្ដាយនឹងទារក ធ្វើឱ្យយើងខ្ញុំមានសុខភាពល្អ ការធ្វើដំណើរទៅមកមានសុវត្ថិភាព ហើយគាត់ពិតជាមានការបារម្ភណ៍ចំពោះពួកខ្ញុំ។ កន្លងមកៗខ្ញុំឮតែគេនិយាយ តែពេលនេះ សុខភាព ខ្ញុំ សន្តិភាព ពិតជាមានមែននៅក្នុងប្រទេសយើង»។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ឆ្នាំរបស់រដ្ឋាភិបាលជាគោលនយោបាយថ្មី អនុវត្តជា៣ដំណាក់កាល។ ដំណាក់កាលទី១៖ ផ្ដល់ការឧបត្ថម្ភចំនួន៤ម៉ឺនរៀល ក្នុងមួយដង សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះចំនួន ៤ដងមុនពេលសម្រាលកូន។ ដំណាក់កាលទី២៖ ផ្ដល់ការឧបត្ថម្ភចំនួន២០ម៉ឺនរៀល តែម្ដងគត់នៅពេលសម្រាលកូន។ និងទី៣៖ ឧបត្ថម្ភចំនួន ៤ម៉ឺនរៀល ក្នុងមួយដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាល ចំនួន ០៤ ដង និងចំនួន ០៦ដង និងសម្រាប់ការនាំកូនមកចាក់ថ្នាំបង្ការក្នុង ០១ លើកៗ រហូតដល់អាយុ ២ឆ្នាំ។

សេចក្ដីប្រកាសនេះ ត្រូវបានធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមទាំងក្រសួងសុខាភិបាល។

ការឧបត្ថម្ភប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះទាំងមុននិងក្រោយសម្រាលនេះ នឹងចាប់ដំណើរការពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ខាងមុខនេះ។

អង្គុយជជែកលេងជាមួយមិត្តភក្តិដែលជាកម្មការិនីរោងចក្រដូចគ្នា អ្នកនាង មុំ សម្រស់ មានវ័យជាង ២៦ឆ្នាំ កំពុងបម្រើការងារនៅក្នុងរោងចក្រ ផលិតគ្រឿងបង្គុំអគ្គិសនីក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រេកអរជាខ្លាំងចំពោះគម្រោងគាំពារស្ត្រីមានផ្ទៃពោះ និងកុមារតូចរបស់រដ្ឋាភិបាលមួយនេះ ខណៈពេលដែលគាត់កំពុងមានផ្ទៃពោះ។

អ្នកនាង មុំ សម្រស់ បាននិយាយថា គាត់បានឮដំណឹងនេះរួចហើយ។ គាត់ក៏បានទទួលព័ត៌មាននេះ ពីថៅកែរោងចក្រ ពីរដ្ឋបាលរបស់រោងចក្រដែលបានផ្សព្វផ្សាយនាពេលកន្លងមកដែរ។

អ្នកនាង សម្រស់ បន្តថា បច្ចុប្បន្នគាត់មានទាំងប័ណ្ណបេឡាជាតិរបបសន្តិសុខសង្គម (បសស) និងប័ណ្ណសមធម៌សុខាភិបាល ដែលបង្កភាពងាយស្រួលដើម្បីទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋនោះ។

អ្នកនាង មុំ សម្រស់ ឱ្យដឹងថា៖ «ខ្ញុំពេញចិត្តគាត់ (សម្ដេចតេជោ) គាត់និយាយជាមួយយើងគាត់មិនកុហក គាត់និយាយថាជួបយើងគឺគាត់ជួប និយាយរួមគាត់បានដឹកនាំល្អ។ ខ្ញុំសប្បាយចិត្តបានគាត់កាន់តំណែងបន្ត ដែលផ្ដល់ប្រយោជន៍ដល់ខ្ញុំបន្តបន្ទាប់ទៀត។ ចង់ឱ្យកាន់ ហើយបន្តឱ្យប្រទេសយើងរីកចម្រើនបន្តទៀត ព្រោះថាគាត់កាន់ (ដំណែង) មានសន្តិភាពល្អ»។



*សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ថតរូបអនុស្សាវរីយ៍ជាមួយកម្មការិនីមានផ្ទៃពោះ។ រូបភាពៈ ហ្វេសប៊ុកសម្ដេចតេជោ*

រដ្ឋមន្ត្រីក្រសួងសុខាភិបាលរបស់ប្រទេសកម្ពុជា ឯកឧត្តម សាស្ត្រាចារ្យវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង បានថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីពេលថ្មីៗនេះថា ការផ្ដល់ជូនស្ត្រី និងកុមារក្រីក្របែបនេះ ដើម្បីលុបបំបាត់អត្រាមរណភាពរបស់មាតា និងទារក និងធ្វើឱ្យកុមារទទួលបានសុខភាពល្អ បញ្ញាឈ្លាសវៃ និងការលូតលាស់ល្អ។

លោករដ្ឋមន្ត្រីឲ្យដឹងទៀតថា តាមរយៈគោលនយោបាយថ្មី ដែលរាជរដ្ឋាភិបាលកំពុងតែបានដាក់ចេញនេះ គឺកំពុងតែធ្វើឱ្យសុខភាពមាតា និងទារកមានភាពប្រសើរឡើង កាត់បន្ថយភាពក្រីក្រ និងអត្រាគ្រោះថ្នាក់ផ្សេងៗ ដែលទាំងនេះជាការគិតគូរ និងយកចិត្តទុកដាក់ពីប្រមុខថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា។

ប្រទេសកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរបស់ខ្លួន ដែលទាក់ទងទៅនឹងការអនុវត្តសុខភាពមុនការកំណត់។ ជាក់ស្ដែងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប កំពុងតែស្ថិតនៅក្នុងអាទិភាពនៃគោលនយោបាយសង្គមកិច្ច ដែលជាចក្ខុវិស័យខ្ពស់។ ផែនការសុខាភិបាល ២០១៦-២០២០ ដែលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា កាន់តែមានសុខភាពល្អប្រសើរ ដើម្បីបម្រើដល់ការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។

តាមគោលការណ៍ចាស់របស់រដ្ឋាភិបាលកាលពីឆ្នាំ២០១៨កន្លងទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់កម្មការិនីសម្រាលកូនមានចំនួនជាង៦ម៉ឺន ៥សែននាក់ និងត្រីមាសទី១ក្នុងឆ្នាំ២០១៩នេះ មានកម្មការិនីដែលសម្រាលកូនចំនួនជិត ២ម៉ឺននាក់។ ហើយគោលការណ៍ថ្មីនេះ នឹងចាប់អនុវត្តនៅដើមខែមិថុនា ឆ្នាំ២០១៩នេះ៕





*សម្ដេចតេជោ ថតរូបអនុស្សាវរីយ៍ជាមួយកម្មការិនីមានផ្ទៃពោះ។ រូបភាពៈ ហ្វេសប៊ុកសម្ដេចតេជោ*












# ស្ត្រីមេផ្ទះមួយចំនួនត្អូញថាសម័យ Facebook ពេលញ៉ាំបាយ លែងមើលមុខគ្នា

*ដោយៈ រឿន ស្រីម៉ាច*

បច្ចេកវិទ្យាបានធ្វើឲ្យមនុស្សកាន់តែងាយស្រួលទំនាក់ទំនងគ្នា ហើយក៏ជារឿងមួយដែលគ្រួសារគួរតែយកចិត្តទុកដាក់ នូវកិច្ចទំនាក់ទំនងគ្នាឡើងវិញផងដែរ។ សម័យទូរសព្ទស្មាតហ្វូនឪពុកម្ដាយនិងកូនៗហាក់ដូចជាដាច់ឡែកចេញពីគ្នា ហើយបានធ្វើឲ្យសង្គមគ្រួសារក្លាយជាសង្គមមួយឯកោ។ ស្ត្រីមេផ្ទះមួយចំនួនបានត្អូញត្អែរនឹងភាពស្ងប់ស្ងាត់ក្នុងផ្ទះ និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមកតែនៅលើបណ្ដាញសង្គម ដែលធ្វើឲ្យបាត់ភាពជិតស្និទ្ធនិងការយល់ចិត្តគ្នារវាងបងប្អូន កូនចៅ និងប្ដីឬប្រពន្ធ។

ការរស់នៅក្នុងគ្រួសារត្រូវការពេលវេលានៅជាមួយគ្នា ជជែកពិភាក្សា ចែករំលែកអំណរសប្បាយ និងរួមសុខទុក្ខជាមួយគ្នា។ ចាប់តាំងពីប្រព័ន្ធអ៊ីធឺណេតបានចាប់ផ្ដើមរីកសុះសាយនៅក្នុងចំណោមប្រជាជន មួយរយៈចុងក្រោយនេះមានស្ត្រីមួយចំនួនដែលជាមេផ្ទះលើកឡើងថាក្នុងផ្ទះមានសភាពស្ងប់ស្ងាត់ ព្រោះដៃកាន់តែទូរសព្ទស្មាតហ្វូនសូម្បីពេលញ៉ាំបាយក៏មិនខ្វល់ថាមានម្ហូបអ្វីលើតុដែរ។ ទង្វើនេះបានធ្វើឲ្យមេចុងភៅក្នុងផ្ទះស្រងាកចិត្តនូវអ្វីដែលខ្លួនខិតខំធ្វើសម្រាប់អ្នកបរិភោគ។

អ្នកស្រី ជិន តុងហ៊ី វ័យ ៤៥ ឆ្នាំជាស្ត្រីមេផ្ទះនៅទីក្រុងភ្នំពេញបានឱ្យដឹងថា ជីវិតគ្រួសារអ្នកស្រីបានខុសប្លែកពីពេលមុន គឺចាប់តាំងពីមានទូរសព្ទគ្រប់ដៃមក អ្វីៗបានផ្លាស់ប្ដូរពីអ៊ូអរមកជាស្ងប់ស្ងាត់ និងដាក់ឡែកពីគ្នា។ អ្នកស្រីបានពោលថា៖ «បើពេលវេលាត្រឡប់បានចង់ឱ្យវិលទៅកាលពីកូននៅក្មេងៗដែលតែងតែហៅម៉ែពុកគ្រប់ពេល សួរម៉ែថាមានអីញ៉ាំ? ទៅណា? មកណា? សុំលុយញ៉ាំនំ? ហើយមានសំលេង សើចសប្បាយពេញផ្ទះតែពេលនេះគឺមិនដូចមុនទេ»។

ក្នុងមួយថ្ងៃៗសមាជិកនៅក្នុងផ្ទះរបស់អ្នកស្រី តុងហ៊ី គឺគ្មានពេលជួបមុខគ្នាច្រើនទេ ដោយសារអ្នកខ្លះត្រូវក្រោកពីព្រឹកព្រលឹមទៅធ្វើការ ហើយខ្លះទៀតទៅរៀន លុះដល់ល្ងាច ឬថ្ងៃអាទិត្យទើបបានជុំគ្នា។ ក្នុងផ្ទះមានសមាជិក៥នាក់ ប៉ុន្តែហាក់ដូចជាគ្មានមនុស្សរស់នៅ ស្ត្រីរូបនេះបន្ថែមថា «គេមានការងារធ្វើមានទូរសព្ទគ្រប់ដៃ។ ម្ហូបខំធ្វើទុកទាំងព្រឹកទាំងល្ងាចគេមិនចាប់អារម្មណ៍ គឺគិតតែពីថតរូប និងចុចទូរសព្ទរហូត។ ខ្ញុំជាម្ដាយអន់ចិត្តហើយគិតថាខ្ញុំលែងសំខាន់សម្រាប់ពួកគេទៀតហើយ»។

មិនសូវខុសគ្នាប៉ុន្មានពីស្ត្រីខាងលើ អ្នកស្រី កៅ នួន វ័យ ៣៣ ឆ្នាំជាអ្នកស្រុកព្រៃឈរ ខេត្តកំពង់ចាមបានឱ្យដឹងផងដែរថា អ្នកស្រីមិនហាមឃាត់ ឬរិទសិទ្ធិកូនៗនិងប្ដីមិនឱ្យប្រើទូរសព្ទទេ សូម្បីតែខ្លួនអ្នកស្រីផ្ទាល់ក៏ប្រើដែរ តែអ្វីដែលសំខាន់នោះគឺសូមតែកុំភ្ជាប់ខ្លួនជាមួយរបស់នោះរហូតភ្លេចអ្វីៗនៅជុំវិញខ្លួន។

អ្នកស្រីនួនថា «កូនញ៉ាំបាយផងលេងហ្គេមផង ប្ដីញ៉ាំផងលេងហ្វេសប៊ុកផង លែងសួរនាំប្រពន្ធដូចមុន។ តើសម្រាប់បាយមួយពេលសមាជិកក្នុងផ្ទះមិនអាចញ៉ាំដោយសប្បាយចិត្តបានទេមែនទេ? ក្នុងនាមជាស្ត្រីមេផ្ទះម្នាក់ពេលខ្លះធុញថប់ក្នុងចិត្ត សឹងស្រក់ទឹកភ្នែកពេលឃើញគេលែងខ្វល់ពីអ្នកដែលខិតខំរៀបចំសម្រាប់គេបែបនេះ»។

សកម្មភាពនេះ មិនសូវខុសគ្នាប៉ុន្មានទេ ពីគ្រួសារមួយទៅគ្រួសារមួយទៀត។ ដេះបើតាមអ្នកស្រី សុខ ឈឿន វ័យ ៥៤ ឆ្នាំជាអ្នកភ្នំពេញនិងអតីតគ្រូបង្រៀនកម្រិតវិទ្យាល័យម្នាក់។ អ្នកស្រីបានឱ្យដឹងដែរថា «ប្រហែលអ្នកម្ដាយមួយចំនួនធំមិនចេះប្រើទូរសព្ទទំនើប ឬលេងហ្វេសប៊ុកដូចកូនៗ គឺមានតែខិតខំយកពេលវេលាទៅធ្វើការរកលុយមកផ្គត់ផ្គង់អ្វីៗគ្រប់យ៉ាងឱ្យកូនៗ។ ហេតុនេះកូនៗខ្ញុំ ពេលណាប្រដៅស្ដីថា គេបោះសម្ដីថាសម័យនេះចឹងហើយ ម៉ាក់មិនយល់ទេ ឬម៉ាក់ដើរមិនទាន់គេសោះ!»។

អ្នកស្រី ឈឿនបន្ថែមថា៖ «ក្នុងជីវិតចុងក្រោយនេះអ្នកម្ដាយទាំងអស់ចង់ឱ្យកូនៗយកពេលវេលាមើលថែ និងមានទំនាក់ទំនងគ្នាដូចជាការនិយាយសរសើរ ឬប្រាប់អំពីអ្វីក្នុងចិត្តច្រើនជាងការដែលកូនមកថតរូប ឬសរសេរអ្វីអរគុណ និងសូមទោសនៅក្នុងហ្វេសប៊ុក។ សូមទុកទូរសព្ទខ្លះមកញ៉ាំអាហារនិយាយពីនេះពីនោះជាមួយគ្នាដោយស្នាមញញឹមច្រើនជាងការផុសម្ហូបដែលមានលើតុ»។

ចំណែកកញ្ញា កែវនេត្រា វ័យ ១៨ឆ្នាំ រស់នៅភ្នំពេញបានឱ្យដឹងថាក្នុងមួយថ្ងៃនាងប្រើទូរសព្ទយ៉ាងហោចណាស់៥ម៉ោងឡើងទៅ។ ការប្រើនេះគឺគ្មានអ្វីក្រៅពីលេងហ្វេសប៊ុក ស្ដាប់ចម្រៀង លេងហ្គេម និងហៅទូរសព្ទចេញខ្លះៗឡើយ។ នេត្រានិយាយថា «បើនៅផ្ទះវិញ គឺអត់សូវបាននិយាយជាមួយម៉ាក់ ឬជួយធ្វើអីគាត់ផង ព្រោះបើអត់ទៅណាទេ គឺនៅក្នុងបន្ទប់លេងទូរសព្ទមើលសៀវភៅតិចតួច ហើយពេលខ្លះម៉ាក់ប៉ារអ៊ូដាក់ដែរ តែមិនសូវចាប់អារម្មណ៍នឹងសម្ដីគាត់»។

នេត្រាបន្តថា «ដឹងថាម៉ាក់ប៉ាខឹងអន់ចិត្តតែគិតថាគាត់ស្រលាញ់ខ្ញុំ ចឹងខ្ញុំមិនខ្វល់ទេ ពេលចង់ធ្វើអីគឺធ្វើ ហើយបើទោះបីជាអត់មានអ្នកណានៅក្បែរគឺមានតែទូរសព្ទទៅគឺបានហើយ»។

នេត្រាបានឱ្យដឹងថា អ្វីៗដែលធ្លាប់គិតកន្លងមក គឺខុសទាំងស្រុង។ នាងបានភ្ញាក់ខ្លួននិងមានវិប្បដិសារី ក្រោយពេលម្ដាយមានជំងឺហើយទទួលមរណភាព។ យុវតីរូបនេះបន្តថា «ខ្ញុំស្ដាយពេលវេលាកន្លងមកដែលមានម៉ាក់គឺអត់បានបំពេញនាទីជាកូនល្អ យកពេលចំណាយទៅលើស្មាតហ្វូនច្រើនជាង។ តែពេលនេះអ្វីៗហួសពេលអស់ហើយ ខ្ញុំសន្យានឹងខ្លួនឯងថានឹងកែខ្លួនជាថ្មី ហើយសូមយុវវ័យទាំងអស់កុំធ្វើដូចខ្ញុំ។ ទូរសព្ទចង់បានបែបណាក៏បានតែពេលវេលានិងអនុស្សាវរីយ៍ល្អៗជាមួយសមាជិកក្នុងផ្ទះ មិនអាចយកលុយទៅទិញបានទេ»។

នៅក្នុងប្រទេសកម្ពុជា អត្រានៃប្រជាជនដែលប្រើប្រាស់ទូរសព្ទចល័តស្មាតហ្វូន គឺមានចំនួនប្រមាណជាង១៩លាននាក់ក្នុងឆ្នាំ២០១៨ ដែលមានអត្រាខ្ពស់ជាងចំនួនប្រជាជនសរុប ១៦លាននាក់ទៅទៀត។ អត្រានៃអ្នកប្រើប្រាស់បណ្ដាញសង្គម ជាពិសេសហ្វេសប៊ុកមានចំនួន ៧លានគណនី នៅក្នុងឆ្នាំ២០១៨៕

# ប្រេងកាត! ចេះតែឮប៉ុន្តែមិនដឹងជាពេលណា? រោងចក្រចម្រាញ់ប្រេងកាតក៏មិនដឹងសាងសង់ដល់ណា?

*ដោយ៖ អរិយបុត្រ*

នៅពេលដែលនិយាយអំពីធនធានប្រេងកាត ពលរដ្ឋកម្ពុជាបានត្រឹមតែទន្ទឹង មិនដឹងជាពេលណា ពួកគេបានឃើញនិងបានទទួលព័ត៌មានអំពីតំណក់ប្រេងកាតនេះឲ្យបានពិតប្រាកដនៅឡើយ។

រហូតមកដល់ពេលនេះប្រជាពលរដ្ឋកម្ពុជានៅតែមានចម្ងល់ថា តើពេលណាបានពួកគេបាន ទទួលព័ត៌មានពិតប្រាកដអំពីប្រេងកាតក្រោយពេលដែលពេលវេលានៃការទទួលតំណក់ប្រេងតំបូង គឺត្រូវពន្យាពេលជាបន្តបន្ទាប់ ហើយគម្រោងផ្សេងៗដែលពាក់ព័ន្ធនឹងប្រេងកាតនេះចេះតែឮជាហូរហែ ប៉ុន្តែវានៅតែមិនទាន់ឃើញសមិទ្ធផលអ្វីចេញជាដុំកំភួននៅឡើយ ក្រៅតែពីកិច្ចប្រជុំ កិច្ចព្រមព្រៀង តែសមិទ្ធិផលសម្រេចពិតប្រាកដមិនមានចេញ។

លោក ផេង សុចិត្រា ជាអាជីវកម្មឃូប បានឲ្យដឹងថា លោក និងប្រជាពលរដ្ឋកម្ពុជាឯទៀតពិតជាចង់ដឹងអំពីវឌ្ឍនភាពនៃវិស័យប្រេងកាតនៅកម្ពុជាមែនទែន ប៉ុន្តែរហូតមកដល់ពេលនេះ គ្មានអ្វីជាដុំកំភួនសោះតែម្តង។

លោកបានឲ្យដឹងថា ព័ត៌មានអំពីធនធានប្រេងកាតនៅកម្ពុជានេះ លោកបានដឹងបានរៀន បានទទួលព័ត៌មានថា កម្ពុជាយើងមានតាំងពីក្មេង តាមរយៈមេរៀនភូមិវិទ្យា ហើយចាប់ពីចុងទសវត្សរ៍ នៃឆ្នាំ១៩៩០ មក ក៏ចេះតែឮគម្រោងនេះច្រើន ប៉ុន្តែតាំងពីនេះមកដល់បច្ចុប្បន្ន គឺឃើញតែព័ត៌មាន។

លោក ផេង សុចិត្រា ដែលបច្ចុប្បន្នមានអាយុ ៣៩ឆ្នាំ បានថ្លែងបញ្ជាក់ថា៖ «ដឹងថា យើងមានតាំងពីរៀននៅថ្នាក់ទី៧ ឬ ទី៨ អីឯណោះ តែពេលនេះ គឺនៅតែបានដឹងចឹង ត្រង់អាតំណក់ពិតប្រាកដអត់ឃើញ»។

លោក វ៉ាន់ ចិន្តា ជាមន្ត្រីវ័យចំណាស់មួយរូប ដែលអះអាងត្រឹមថា ជិតចូលនិវត្តិន៍បានថ្លែងថា ពេលដែលឮព័ត៌មានអំពីប្រេងកាតនេះចេះតែព្យាយាមតាមដាន ប៉ុន្តែតាំងពីតាមដានជាង ១០ឆ្នាំ ហើយ គឺឃើញតែព័ត៌មាន តែមិនដឹងពេលណាបានឃើញ។

លោកបានថ្លែងថា តាំងពីក្មេងរហូតមកដល់អាយុចំណាស់ជាង ៦០ឆ្នាំទៅហើយ គឺបានត្រឹមតែទទួលព័ត៌មានថា យើងមានកំណប់រ៉ែប្រេងកាតនេះច្រើននៅឈូងសមុទ្រ ហើយកន្លែងខ្លះនៅលើគោកនេះក៏មានដែរ ប៉ុន្តែឃើញតែព័ត៌មានទេ។

លោកបានបញ្ជាក់ថា៖ «មិនដឹងជាខ្ញុំមានសំណាងអាចបានឃើញ អាតំណក់ប្រេងដំបូងនេះបានឬអត់ទេ ពីព្រោះវាដូចជាយូរពេកហើយ»។

លោក គាង ឃៀង ជាអាជីវករមួយរូប ក៏បានថ្លែងថា លោកចេះតាមដានព័ត៌មានរឿងប្រេងកាត នេះតាំងពីអានកាសែតនៅតាមតុកាហ្វេ រហូតដល់ឥឡូវដល់ថ្នាក់ចេះតាមខ្លះតាមទូរសព្ទស្មាតហ្វូនខ្លះៗនឹងគេដែរ តែនៅតែមិនសូវឮអំពីលទ្ធផលនៃរឿងប្រេងកាតនេះ។

លោកបានបន្តថា ស្ងាត់មួយរយៈទៅ ក៏ឮមួយប្រាវទៀតទៅ ហើយក៏ស្ងាត់ទៅវិញទៅរាប់ឆ្នាំហើយដល់ថ្នាក់ស៊ាំ។

លោកបានរៀបរាប់ថា ឥឡូវចង់នឿយនឹងរំភើបរឿងតំណក់ប្រេងនេះហើយ ពីព្រោះឮតែខ្យល់ ជិតដូចជាជាង ២០ឆ្នាំហើយដឹង។

លោកបានបន្តថា រឿងប្រេងកាតនេះលោកបានតាមដានព័ត៌មានជាប់ដែរ ទើបតែខានប៉ុន្មានឆ្នាំនេះដែរ ពីព្រោះខ្វិលរវល់។

លោកបានបញ្ជាក់ថា៖ «តាមចាំ គឺមានទាំងរឿងកំណត់ឆ្នាំដែលទទួលតំណក់ប្រេងដំបូង រឿងតាំងពី សាងសង់រោងចក្រចម្រាញ់ប្រេងកាតថែមទៀត តែឥឡូវដូចជាស្ងាត់តែទាំងអស់»។

នេះគឺជាអ្វីដែលបង្ហាញពីភាពអន្ទះសារ និងគោលបំណងរបស់ពលរដ្ឋនៅកម្ពុជាទាក់ទងនឹងធនធានរ៉ែប្រេងកាត ដែលមកដល់បច្ចុប្បន្ននេះ គឺកំពុងតែមានតម្លៃ និងជាប្រភពថាមពល ដ៏ចម្បង ដែលនរណាក៏ចង់បាន នរណាក៏កំពុងតែប្រើប្រាស់ដោយខានមិនបាន។ ប៉ុន្តែខាងសមត្ថកិច្ចជំនាញឯណោះវិញ គឺនៅតែបន្ត អភិវឌ្ឍកិច្ចការលើកំណប់រ៉ែនេះ ជាជំហានៗហើយ។

## មិនដឹងជាខ្ញុំមានសំណាងអាចបានឃើញអាតំណក់ប្រេងដំបូងនេះបានឬអត់ទេ ពីព្រោះវាដូចជាយូរពេកហើយ ”

ឈានចូលមកដល់សប្តាហ៍ទី២ នៃខែមិថុនា ឆ្នាំ២០១៩ នេះ ទាក់ទិននឹងរឿងប្រេងកាតនេះ គឺឈានដល់ដំណាក់កាលមួយដែលគណៈកម្មការជំនាញរដ្ឋសភា និងរាជរដ្ឋាភិបាលកំពុងតែធ្វើការជាមួយគ្នា ដោយពួកគេកំពុងពិនិត្យពិភាក្សាចុងក្រោយលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។

យោងទៅតាមអគ្គលេខាធិការដ្ឋានរដ្ឋសភា គណៈកម្មការជំនាញរដ្ឋសភា និងរាជរដ្ឋាភិបាល បានធ្វើការពិនិត្យពិភាក្សាចុងក្រោយលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត ហើយគ្រោងនឹងដាក់ជូនអង្គសភាអនុម័តក្នុងពេលឆាប់ៗខាងមុខ។









កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩ កន្លងទៅនេះ លោកស្រី និន សាផុន ប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូនទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ និងថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃរដ្ឋសភា បានសហការជាមួយអន្តរគណៈកម្មការជំនាញរដ្ឋសភាបានបើកកិច្ចប្រជុំជាលើកចុងក្រោយជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ លោក ស៊ុយ សែមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងសហការី ដើម្បីពិនិត្យពិចារណានូវសំណើរទាំងនោះ នៅវិមានរដ្ឋសភា។

ក្រោយពីបានពិភាក្សាគ្នាបន្ថែមរវាងអន្តរគណៈកម្មការនៃរដ្ឋសភាជាមួយតំណាងរាជរដ្ឋាភិបាល នាពេលនេះ គណៈកម្មការនៃរដ្ឋសភាបានឯកភាពគ្នា បញ្ជូនសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត ដែលមាន៩ជំពូក និង៧២មាត្រានេះជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ រដ្ឋសភាវិញ ដើម្បីសម្រេចបញ្ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភានាពេលខាងមុខ។

នៅក្នុងកិច្ចពិភាក្សានោះ លោក ស៊ុយ សែម បានមានប្រសាសន៍ឲ្យដឹងថា សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត តាក់តែងឡើងដើម្បី ឱ្យស្របនឹងបរិបទនៃវិស័យប្រេងកាតនៅកម្ពុជា និងជំរុញការអភិវឌ្ឍវិស័យប្រេងកាតប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងផលប្រយោជន៍យូរអង្វែងរបស់ប្រទេសជាតិ។ លោកបន្តថា សេចក្តីព្រាងច្បាប់នេះ បានរៀបចំឡើងបន្ទាប់ពីរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន គ្រីសអ៊ីណឺជី (KrisEnergy) បានចុះកិច្ចព្រមព្រៀងជាមួយគ្នាកាលពីឆ្នាំ២០១៧ សម្រាប់ការអភិវឌ្ឍអណ្តូងប្រេងកាតនៅក្នុងប្លុកA នៃដែនសមុទ្រកម្ពុជា។

លោករដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានឱ្យដឹងទៀតថា ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាពក្នុងវិស័យប្រេងកាតនៅក្នុងបូរណភាពទឹកដី និងអធិបតេយ្យនៃកម្ពុជា រួមទាំងបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀត។

លោកបានគូសបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះ បានតាក់តែងឡើងស្របតាមបទដ្ឋាន និងឧត្តមានុភាពជាអន្តរជាតិក្នុងវិស័យរ៉ែ ព្រមទាំងបានការពារដល់បរិស្ថាន និងធនធានធម្មជាតិដោយនិរន្តរភាព។ ការតាក់តែងសេចក្តីព្រាងច្បាប់នេះ ក៏មានការជួយគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញការច្បាប់ជាតិ និងអន្តរជាតិផងដែរ។

នាឱកាសនោះ លោក ស៊ុយ សែម ក៏បានលើកឡើងថាកម្ពុជាមានប្លុកប្រេងកាតដែលអាចបូមបានចំនួន ២៥កន្លែងនៅក្នុងដែនសមុទ្រ និងដែនគោក ខណៈមានការអះអាងថាតំណក់ប្រេងដំបូងអាចទាញយកមកប្រើប្រាស់នៅចុងឆ្នាំ២០១៩នេះ។







*ផែនទីបង្ហាញពីប្លុកប្រេងក្នុងបណ្តាប្រទេសក្នុងតំបន់។*

គួររំលឹកថា ពង្រាងច្បាប់នេះត្រូវបានឆ្លងគណៈរដ្ឋមន្ត្រីកាលពីខែ មេសា ឆ្នាំ ២០១៩ ដើម្បីដាក់ជូនរដ្ឋសភាអនុម័ត មុនពេលបញ្ជូនទៅព្រឹទ្ធសភា និង ព្រះមហាក្សត្រឡាយព្រះហស្ថលេខា ដើម្បីឲ្យវាមានសុពលភាព។

ហើយដោយឡែក ទាក់ទិននឹងតំណក់ប្រេងដំបូងវិញ កាលពីឆ្នាំទៅ ក្រុមហ៊ុនគ្រីសអ៊ីណឺជី បានអះអាងថា ក្រុមហ៊ុនដែលកំពុងតែរុករករ៉ែប្រេងកាត និងឧស្ម័ន នៅប្លុក អេ នៃឆ្នេរសមុទ្រកម្ពុជា នឹងទទួលតំណក់ប្រេងដំបូងនៅក្នុងរង្វង់ត្រីមាសទី៣ នៃឆ្នាំ២០១៩នេះ។

តាមការរំពឹងទុករបស់ក្រុមហ៊ុន គឺថា អណ្តូងរ៉ែប្រេងកាតនេះអាចមានសក្តានុពលទាញយកកំហាប់ប្រេងឧស្ម័ន និងទឹក ប្រមាណជា ៣០.០០០ បារ៉ែល នៅក្នុងមួយថ្ងៃ។

កាលពីឆ្នាំ ២០១៧ ក្រសួងរ៉ែ និងថាមពល បានប្រកាសថា កម្ពុជារោងចក្រចម្រាញ់ប្រេងកាតមួយដែលមានតម្លៃវិនិយោគសរុប ១,៦ពាន់លានដុល្លារ។ រោងចក្រចម្រាញ់ប្រេងកាតនេះ អាចនឹងមានសមត្ថិភាពផលិតនៅក្នុងរង្វង់ប្រមាណជា ៥លានតោនដែលលើសពីសេចក្តីត្រូវការនៃតម្រូវការប្រេងឥន្ធនៈនៅកម្ពុជា ហើយផលិតផលដែលនៅសល់នឹងនាំចេញ។

ប្រភពដដែលនេះ បានឲ្យដឹងថា រោងចក្រនេះមានឈ្មោះថា ឃែមបូឌៀ ប៉េត្រូគីមី (Cambodian Petrochemical Co ) ដោយដំណាក់កាលដំបូងដែលមានតម្លៃ ៦២០លានដុល្លារ គ្រោងនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០១៩ នេះ ជាមួយនឹងសមត្ថភាពផលិតប្រមាណជា ២លានតោន សម្រាប់ផ្គត់ផ្គង់ទីផ្សារនៅក្នុងស្រុក ប៉ុន្តែសេចក្តីរាយការណ៍ព័ត៌មានចុងក្រោយបង្ហាញថា គម្រោងនេះត្រូវបានពន្យាពេល។

យោងទៅតាមសេចក្តីរាយការណ៍របស់កាសែតខ្មែរថៃមស៍ បានឲ្យដឹងថា គម្រោងដំណាក់កាលទីមួយនៃរោងចក្រចម្រាញ់ប្រេងដែលគ្រោងសាងសង់នៅលើផ្ទៃដី ៣៦៥ម៉ែត្រការ៉េ នៅខេត្តព្រះសីហនុ និងកំពតនឹងពន្យាពេលទៅឆ្នាំក្រោយ៕



មានយុវជនចូលរួមពីព្រះសហគមន៍ចំនួន១៨។
*រូបភាព៖ ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម*

# យុវជនធ្វើបូជនីយចរ អប់រំជំនឿ

*ដោយ៖ រិទ្ធី*

យុវជនយុវនារីចូលរួមចំនួន១២០នាក់ បាននាំគ្នាធ្វើដំណើរបូជនីចរ នៅខេត្តស្ទឹងត្រែង ក្រោមប្រធានបទ៖ «ខ្ញុំជាអ្នកបម្រើព្រះជាម្ចាស់សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គ» កាលពីថ្ងៃទី១២ដល់១៥ ខែឧសភា ឆ្នាំ២០១៩។

លោកបូជាចារ្យ សែ សាត មានប្រសាសន៍ថា គោលដៅដែលសំខាន់បំផុត គឺយើងចង់អប់រំយុវជនយុវនារីយល់ដឹងអំពីសាសនាកាតូលិកឲ្យបានកាន់តែស៊ីជម្រៅក្នុងដួងចិត្តរបស់ពួកគេ លើសពីនេះគឺចង់អប់រំចិត្តកាយ ឲ្យពួកគាត់ចេះចែករំលែកនូវសេចក្ដីត្រូវការរបស់អ្នកដទៃដែលខ្វះខាត ឲ្យពួកគេចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ចេះចែករំលែកនូវចំណេះដឹងថ្មីដល់គ្នានិងគ្នា ចេះអត់ទោសឲ្យគ្នា ចេះផ្សះផ្សាជាមួយគ្នាជាធ្លុងតែមួយនៅក្នុងព្រះយេស៊ូគ្រីស្ត។

នៅក្នុងកម្មវិធីនេះ មានយុវជនចូលរួមពីព្រះសហគមន៍ចំនួន១៨ ដែលស្ថិតនៅក្នុងភូមិភាគកំពង់ចាម រួមមាន ចម្លាក់, ក្តុលលើស្ទឹងត្រង់, ឆ្លូង ក្រចេះ ឃ្សឹម, ផ្កាដូង សួង មេមត់, រលៀក, ភូមិថ្មី, កោះរកា, ព្រៃវែង ព្រែកក្របៅ, ព្រែកពោធិ៍, ស្វាយរៀង បាវិត, និងអ្នកលឿង។

នៅក្នុងកម្មវិធីបូជនីចរ រយៈពេល៤ថ្ងៃនេះ បានចែកចេញ ជាប្រធានបទតូចៗជាច្រើនតាមដំណាក់កាលនៃការធ្វើដំណើររបស់យុវជន ដោយក្នុងនោះមានលោកបូជាចារ្យ ផាន ប៉ូរី ដឹកនាំយុវជនដើរបូជនីយចរដែលនិយាយអំពីការធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់, យ៉ោត មិញ បកស្រាយអំពី ការកកើតជីវិតមនុស្ស សត្វ រុក្ខជាតិនិងអ្វីផ្សេងៗដែលព្រះជាម្ចាស់បានបង្កើតឡើងដំបូងគេ, លោកបូជាចារ្យ សែ សាត បង្រៀនអំពីសន្តិភាពជាមួយអ្នកដទៃ និងចំពោះខ្លួនឯង និងលោក ផាន ប៉ូរ៉ា ពន្យល់អំពីការផ្សះផ្សាជាមួយអ្នកដទៃ ជាមួយបងប្អូន ជាមួយមិត្តភក្តិ ជាមួយបងប្អូនដែលកាន់ខាងសាសនាដទៃ និងផ្សះផ្សាជាមួយព្រះជាម្ចាស់៕



*ការជួបជុំរបស់អង្គការ ស្ថានប័នកាតូលិកក្រោមអធិបតីភាពរបស់លោក អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ រូបភាព៖ លី សុវណ្ណា*

# កិច្ចប្រជុំ អង្គការ ស្ថានប័នកាតូលិក ដែលបម្រើជនមានពិការភាព

*ដោយ៖ លី សុវណ្ណា*

អង្គការ ស្ថាប័ននៃព្រះសហគមន៍កាតូលិកចំនួន១៥ ដែលកំពុងបម្រើការងារជាមួយជនមានពិការភាព កាយសម្បទា និងខ្សោយសតិបញ្ញា បានជួបជុំគ្នា ក្រោមអធិបតីភាពរបស់លោកអូលីវីយេអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក្នុងគោលបំណងបង្កើតបណ្តាញសេវាកម្ម បង្កើនទំនាក់ទំនងចែករំលែកបទពិសោធន៍ការងាររវាងគ្នាទៅវិញទៅមក។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី ១៨ ខែ មិថុនាឆ្នាំ២០១៩ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល នាសង្កាត់ភ្នំពេញថ្មី។

លោកអភិបាលអូលីវីយេមានប្រសាសន៍ថា ថ្ងៃនេះគ្រប់ស្ថាប័ននៅក្នុងព្រះសហគមន៍កាតូលិក និងស្ថាប័នដែលជាដៃគូជាមួយព្រះសហគមន៍កាតូលិកជួបជុំគ្នា ដើម្បីឲ្យអ្វីដែលយើងមានតាមសាលា តាមអង្គការ ក្រុមបព្វជិតបព្វជីតាដែលកំពុងផ្តល់សេវាកម្មដល់ជនមានពិការភាពអាចជួយគ្នាទៅវិញទៅមកបម្រើផលប្រយោជន៍ដល់ជនមានពិការភាព និងដើម្បីឲ្យសេវាកម្មដែលយើងអាចទទួលជោគជ័យនៅពេលអនាគត។

នៅក្នុងកិច្ចប្រជុំនេះ លោក ចេក ចាន់នី ប្រធានស្តីទីផ្នែកសមាហរណកម្មជនពិការនៃក្រសួងសង្គមកិច្ច បានធ្វើបទបង្ហាញ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីវិធីសាស្ត្រនានាដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែអនុវត្ត ដើម្បីជួយសម្រួលដល់ជនដែលមានពិការភាពទាំងនោះឲ្យទទួលបានការអប់រំ សេវាសុខភាព និងសេវាសាធារណៈនានាដូចប្រជាពលរដ្ឋឯទៀតៗ ជាពិសេសលើសិទ្ធិទទួលបានការងារធ្វើ។

លោក នូ សារិទ្ធិ ប្រធានផ្នែកគ្រោះមហន្តរាយនៅអង្គការការីតាសកម្ពុជា ដែលបានចូលរួមបានឲ្យដឹងថា

បទបង្ហាញរបស់ក្រសួងសង្គមកិច្ច បានបង្ហាញច្បាស់ អំពីច្បាប់ផ្សេងៗដែលទាក់ទងទៅនឹងពិការភាព ជាមួយរចនាសម្ពន្ធរបស់រាជរដ្ឋាភិបាល ព្រមទាំងដឹងអំពីនីតិវិធីក្នុងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធទៅនឹងពិការភាព។

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក៏ដូចជានៅក្នុងប្រទេស កម្ពុជាទាំងមូល បានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ក្នុងការយកចិត្តទុកដាក់បម្រើ ផ្តល់សេវាកម្មនានាចំពោះជនមានពិការភាព កាយសម្បទា និងខ្សោយសតិបញ្ញា ដើម្បីឲ្យបងប្អូនទាំងនោះចូលរួមនៅក្នុងសង្គមដូចមនុស្សធម្មតា។ អង្គការស្ថាប័នទាំង១៥ ព្រមទាំងព្រះវិហារនានាតាមកន្លែងនីមួយៗទូទាំងប្រទេស ជាសេនាធិការ៕





*សមាជិកនៃអង្គការ ស្ថាប័នចូលរួមក្នុងកម្មវិធីដើម្បីបង្កើនទំនាក់ទំនង ចែករំលែកបទពិសោធន៍រវាងគ្នាទៅវិញទៅមក។ រូបភាព៖ លី សុវណ្ណា*







*បងស្រី តេរេសា ចាន់ វឌ្ឍា និងបងស្រី ក្លារ៉ា ពេន ហ៊ីល ថ្វាយពាក្យសច្ចា។*

# ឆ្នាំដំបូងក្នុងជីវិតដូនជីស្រលាញ់ឈើឆ្កាងព្រះយេស៊ូ

*ដោយ៖ លី សុវណ្ណា*

ដូនជីវ័យក្មេងនៃក្រុមអ្នកស្រលាញ់ឈើឆ្កាងព្រះយេស៊ូ ចំនួនពីររូបបានថ្វាយពាក្យសច្ចារបស់ខ្លួនបន្តមួយឆ្នាំទៀត ក្រោយពីបានថ្វាយពាក្យសច្ចាលើកទីមួយ កាលពីឆ្នាំ២០១៨។

បងស្រីតេរេសា ចាន់ វឌ្ឍា និងបងស្រី ក្លារ៉ា ពេន ហ៊ីល បានថ្វាយពាក្យសច្ចារបស់ខ្លួនបម្រើក្នុងក្រុមគ្រួសារអ្នកស្រលាញ់ឈើឆ្កាងព្រះយេស៊ូ ក្នុងភូមិភាគកំពង់ចាម នៅចំពោះមុខព្រះសហគមន៍ និងបងស្រីប្រធានក្រុម ដែលមានលោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យជាអធិបតី។

ក្រោយពីថ្វាយពាក្យសច្ចាលើកដំបូង បងស្រីទាំងពីរ ត្រូវបានបងស្រីប្រធាន ចាត់ឲ្យបំពេញកិច្ចក្នុងព្រះសហគមន៍ផ្សេងពីគ្នា គឺបងស្រី ក្លារ៉ា ពេន ហ៊ីល ទៅព្រះសហគមន៍ស្ទឹងត្រែង ចំណែកបងស្រី តេរេសា ចាន់ វឌ្ឍា ទៅព្រះសហគមន៍នៅខេត្តព្រៃវែង។

រយៈពេលមួយឆ្នាំក្នុងជីវិតជាដូនជីកាតូលិក បងស្រី ក្លារ៉ា ពេន ហ៊ីល បានប្រាប់អ្នកនាំសារថា ការរស់នៅខាងក្រៅក្រុមក្នុងនាមជាបងស្រីគឺខុសគ្នា ឆ្ងាយណាស់ពីការរៀនក្នុងផ្ទះអ្នកបួសនៅកំពង់ចាម។ ការជឿទុកចិត្ត លើព្រះជាម្ចាស់ក៏មានការសង្ស័យច្រើនណាស់ដែរ។ ពេលអធិដ្ឋានម្នាក់ឯង ពេលខ្លះខកខានក្នុងការអធិដ្ឋានតាមពេលកំណត់ ព្រោះតែកិច្ចការរវល់ច្រើននៅក្នុងដៃ។ «ខ្ញុំមានអារម្មណ៍ថា អធិដ្ឋានដូចជាមិនបានជួបព្រះជាម្ចាស់ទេ។ ស្វែងរកព្រះជាម្ចាស់ពិបាកមែនទែន។ ជីវិតខាងវិញ្ញាណរបស់ខ្ញុំក្នុងមួយឆ្នាំនេះពិបាកបំផុត ក្នុងការទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ខ្ញុំមានអារម្មណ៍ឯកោជាមួយព្រះជាម្ចាស់»។

មិនសូវខុសគ្នាពីបងស្រី ពេនហ៊ីល ទេ បងស្រី តេរេសា ចាន់វឌ្ឍា ក៏បានប្រាប់អ្នកនាំសារដែរថា ក្នុងរយៈពេលមួយឆ្នាំដែលចេញបំពេញកិច្ចការ ក្នុងមុខងារជាបងស្រី គឺមានការខ្វល់ខ្វាយច្រើនអំពីកិច្ចការត្រូវបំពេញ ពេលខ្លះភ្លេចខ្លួនខកខានអធិដ្ឋានតាមពេលកំណត់ដែរ។ ទោះជាយ៉ាងនេះក្តី បងស្រី តេរេសា ចាន់ វឌ្ឍា បាននិយាយថា៖ «ខ្ញុំបានត្រៀមខ្លួនរួចស្រេចហើយ និងព្យាយាមទៅរកព្រះជាម្ចាស់។ ថ្វាយសេចក្តីទាំងប៉ុន្មានទៅព្រះជាម្ចាស់។ជួបជាមួយបងប្អូន»។

សព្វថ្ងៃនេះបងស្រី ពេនហ៊ីល រស់នៅដាច់ដោយឡែកពីក្រុម ហើយខិតខំ រក្សាពាក្យសច្ចារបស់ខ្លួនដែលបានថ្វាយទៅព្រះជាម្ចាស់។ ពេលមានទុក្ខលំបាក បងស្រី បានគិតថា ព្រះជាម្ចាស់បានដាក់វិញ្ញាសារចំពោះខ្លួន ហើយលទ្ធផលនោះគឺអាស្រ័យលើព្រះជាម្ចាស់។

បងស្រីរូបនេះបន្តថា គាត់ខិតខំស្វែងរកព្រះជាម្ចាស់ តាមរបៀបរស់នៅប្រចាំថ្ងៃ និងតាមរយៈជីវិតរបស់សន្ត សន្តី និងបុគ្គលដែលជាគំរូនៃជំនឿ។ បងស្រី ហ៊ីល៖ «ខ្ញុំតែងចោទសួរថា ពួកគាត់តស៊ូរបៀបណា? ខ្ញុំមានសំណួរបែបនេះពេលអស់កម្លាំងពីការងារផ្ទាល់ខ្លួន និងអស់កម្លាំងក្នុងការទំនាក់ទំនងជាមួយព្រះជាម្ចាស់»។



ជាងនេះទាំងបងស្រី វឌ្ឍា និងបងស្រី ក្លារ៉ា ពេន ហ៊ីល បាននិយាយដូចគ្នា ថា៖ «ពេលខ្ញុំបានជួបបងប្អូន ស្តាប់ទុក្ខលំបាករបស់បងប្អូននាំឲ្យមានអំណរសប្បាយកើតឡើងយ៉ាងពិតប្រាកដ»។

បងស្រី តេរេសា ចាន់ វឌ្ឍា បាននិយាយថា ពេលទាក់ទងជាមួយបងប្អូន និងបំពេញកិច្ចការសម្រាប់បងប្អូន នាំឲ្យគាត់យល់ថា ជីវិតមានតម្លៃ និងមានអំណរសប្បាយ។ បងស្រីវឌ្ឍាលើកឡើងថា៖ «តាមជំនឿ គឺយល់ថាធ្វើកិច្ចការតូចតាច តែយល់ថាមានតម្លៃ។ អំណរសប្បាយចេញពីទុក្ខផង និងចេញពីអំណរសប្បាយផង»។

បងស្រីក៏បាន បន្តថា «ក្រោយសច្ចាខ្ញុំមានជំងឺបេះដូង។ បងប្អូនមិនបោះបង់ខ្ញុំ យកចិត្តទុកដាក់ ធ្វើឲ្យខ្ញុំយល់ចិត្តរបស់បងប្អូន។ ខ្ញុំលះបង់បន្តិចបន្តួចតែព្រះជាម្ចាស់ ប្រទានឲ្យខ្ញុំច្រើនជាង»។

ដូចគ្នានេះដែរ បងស្រី ក្លារ៉ា ពេន ហ៊ីល និយាយថា៖ «ខ្ញុំជឿថា ក្នុងទុក្ខលំបាកនេះ ព្រះយេស៊ូនៅជាមួយខ្ញុំ ដើរជាមួយខ្ញុំ ដឹកដៃខ្ញុំជានិច្ច។ ពេលខ្ញុំជួយបងប្អូន គឺបានជួយដល់ខ្លួនខ្ញុំផ្ទាល់ ឲ្យបានចម្រើនឡើងក្នុងជំនឿ ស្មារតីឲ្យមាំឡើង ដូចយកកូនសោរចាក់ភ្ជាប់ជាមួយព្រះយេស៊ូ»។

បងស្រី ក្លារ៉ា ពេន ហ៊ីល បន្តទៀតថា៖ «បម្រើព្រះសហគមន៍ខ្ញុំមានអំណរសប្បាយណាស់ មានសុភមង្គលណាស់ ព្រោះជាកិច្ចការដែលខ្ញុំចូលចិត្ត។ ខ្ញុំប្រាថ្នាបម្រើព្រះយេស៊ូស្រលាញ់ព្រះជាម្ចាស់ ក្នុងគ្រប់កិច្ចការជានិច្ច»។

បងស្រីទាំងពីរក៏បានលើកទឹកចិត្តយុវជនទាំងអស់ដែលរិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ ត្រូវមានចិត្តក្លាហាន មានកម្លាំង ហ៊ានឆ្លើយតបចំពោះព្រះអង្គ ទុកចិត្តលើព្រះហឫទ័យរបស់ព្រះជាម្ចាស់ ស្តាប់ព្រះអង្គ បន្ទាបខ្លួន ទុកឲ្យព្រះអង្គធ្វើការក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យយើងដើរតាមមាគ៌ារបស់ព្រះអង្គ៕

# លោកអភិបាលអូលីវីយេ៖ «យើងជាគ្រីស្ត ត្រូវយកគំរូតាមព្រះនាងម៉ារី »

នៅថ្ងៃបុណ្យគោរពព្រះនាងម៉ារីជាមាតានៃព្រះសគមន៍កាតូលិក កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ លោកអភិបាលអូលីវីយេបានជំរុញឲ្យគ្រីស្តបរិស័ទទាំងអស់ ដែលជួបជុំគ្នានៅព្រះសហគមន៍អរិយក្សត្រ ឲ្យយកគំរូតាមព្រះនាងម៉ារី។


លោកអភិបាលអូលីវីយ និងគ្រីស្តបរិស័ទគោរពរូបសំណាកព្រះនាងម៉ារីនៅព្រះសហគមន៍អរិយក្សត្រ។ រូបភាព៖ ស៊ីអេសស៊ី

លោកអភិបាលបានលើកឡើងនូវសកម្មភាពសំខាន់ៗក្នុងជីវិតរបស់ព្រះនាងម៉ារីយ៉ាងនេះថា ព្រះនាងម៉ារីស្ម័គ្រចិត្តដោយអំណរសប្បាយក្នុងការទទួលយកព្រះយេស៊ូនៅក្នុងផ្ទៃ។ ព្រះនាងម៉ារីបានប្រសូតព្រះយេស៊ូមកលើផែនដីយើង។ នេះជាអំណរសប្បាយរបស់ព្រះនាងម៉ារីពិតមែន។

លោកថា ព្រះនាងម៉ារីជាសាវ័កដំបូងបង្អស់ដែលនៅជិតព្រះយេស៊ូក្នុងដំណាក់កាលដ៏សំខាន់បំផុត គឺពេលព្រះអង្គរងទុក្ខលំបាក។ ជាសាវ័កដែលមានចិត្តស្មោះត្រង់ ចិត្តស្រឡាញ់ ចិត្តលះបង់ និងចិត្តបម្រើ និងជាសាវ័កដែលយល់ចិត្តព្រះយេស៊ូជាងគេ។ ព្រះនាងចូលយ៉ាងជ្រៅទៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងច្បាស់ជាងគេ ។

លោកអភិបាលបន្តថា៖ ព្រះនាងម៉ារីជាគំរូយ៉ាងពិសេសរបស់យើងទាំងអស់គ្នា ដែលយើងបានទទួលពិធីជ្រមុជទឹកទៅជាសាវ័ករបស់ព្រះយេស៊ូ។ នៅថ្ងៃបុណ្យទី៥០ ព្រះនាងម៉ារីទទួលអណ្តាតភ្លើងជាមួយក្រុមគ្រីស្តទូតមួយចំនួន។ មិនមែនលោកសិលាទេ ដែលចេញទៅប្រកាសដំណឹងល្អមុនគេ គឺព្រះនាងម៉ារីទេ ដែលបានចេញទៅប្រកាសដំណឹងល្អមុនគេ។

លោកបញ្ជាក់ទៀតថា ព្រះនាងម៉ារីមានបេះដូងថ្លា មានបេះដូងបរិសុទ្ធ ព្រះនាងជាជនដ៏វិសុទ្ធ។ ជាជនសាមញ្ញដូចយើង ប៉ុន្តែ ព្រះជាម្ចាស់បានលើកព្រះនាងឡើងស្ថានបរមសុខមុនគេបង្អស់នៅថ្ងៃទី១៥ ខែសីហា។ ព្រះនាងម៉ារីចាប់ដៃយើង ធ្វើដំណើរជាមួយយើង ណែនាំយើងឲ្យទៅស្ថានបរមសុខ ដែលព្រះជាម្ចាស់គង់នៅ ជាស្ថានពោរពេញដោយសេចក្តីស្រលាញ់របស់ព្រះអង្គ ជាស្ថានដែលព្រះនាងម៉ារីទៅមុនគេបង្អស់។

លោកអភិបាលរំលឹកគ្រីស្តបរិស័ទទាំងអស់ទៀតថា៖ ព្រះនាងម៉ារីទន្ទឹងរង់ចាំយើងឲ្យចូលស្ថានបរមសុខដែរ។ ពីមួយថ្ងៃទៅមួយថ្ងៃ ព្រះនាងជំរុញយើង ឲ្យយកចិត្តទុកដាក់បម្រើអធិដ្ឋានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ និងយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រមទាំងឲ្យយើងកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត។

លោកបន្តថា ព្រះសហគមន៍ជាសញ្ញាសម្គាល់ពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលនាំឲ្យយើងនឹកឃើញដល់ព្រះនាងម៉ារីជាព្រះមហាក្សត្រីនៃសុខសន្តិភាព។ ឲ្យអធិស្ឋានដើម្បីសុខសន្តិភាពនៅលើពិភពលោក ឲ្យទូលអង្វរព្រះនាងម៉ារីកុំឲ្យយើងខ្លាច ឲ្យយើងម្នាក់ៗទៅជាសាវ័ក ដូចព្រះនាងម៉ារីដែលបម្រើដែលស្រលាញ់ ដែលយកចិត្តទុកដាក់នឹងព្រះហឫទ័យព្រះជាម្ចាស់ ឲ្យកសាងព្រះសហគមន៍របស់ព្រះជាម្ចាស់នៅលើពិភពលោកយើង។

យុវជន ឆាន ស្រីអែម មកពីព្រះសហគមន៍ក្តុលលើ ខេត្តត្បូងឃ្មុំ ដែលបានចូលរួមពីធីបុណ្យនេះបានផ្តល់សក្ខីភាពថា៖ «រាល់ដងមុននឹងធ្វើអ្វី ខ្ញុំតែងតែអធិដ្ឋានសូមព្រះនាងម៉ារីជួយឲ្យខ្ញុំមានកម្លាំង ដើម្បីបន្តដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ និងជួយការពារក្រុមគ្រួសាររបស់ខ្ញុំ»។

ស្រីអែម ពេលទទួលអគ្គសញ្ញាជ្រមុជទឹកបានជ្រើសយក ព្រះនាងម៉ារីជាសន្តីឧបការីរបស់ខ្លួន។ នាងនិយាយថា៖ «ខ្ញុំសប្បាយចិត្តដោយមានសន្តីឈ្មោះម៉ារី ព្រោះព្រះនាងម៉ារីជាម្តាយខ្ញុំផង ជាម្តាយនៃក្រុមគ្រួសារខ្ញុំផង គឺធ្វើឲ្យខ្ញុំមានភាពកក់ក្តៅ មានកម្លាំងបន្តក្នុងកិច្ចការងារ»។ ស្រីអែមបញ្ជាក់ថា៖ «ជាពិសេសនៅពេលបួនទីមួយរបស់ខ្ញុំដែលមានរាងតូចបានសម្រាលកូន ខ្ញុំបានអធិដ្ឋានទៅកាន់ព្រះនាងម៉ារីសូមឲ្យជួយការពារទាំងម្តាយនិងកូន ហើយពួកគេពិតជាបានផុតពីគ្រោះថ្នាក់មែន។ ព្រះនាងថែរក្សាយើង»៕

# កុមារយល់ដឹងពីសិទ្ធិរបស់ខ្លួនក្នុងទិវាកុមារអន្តរជាតិ

ដោយ៖ រិទ្ធី

ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមបានប្រារព្ធកម្មវិធីទិវាសិទ្ធិកុមារអន្តរជាតិលើកទី៧០ ដែលមានក្មេងៗចូលរួម២០០នាក់

បងស្រី ស្រី សុជាតិ តំណាងឲ្យលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមមានប្រសាសន៍រំលឹកកុមារអំពីសិទ្ធិរបស់ពួកគេ ចំនួនបួនធំៗ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការការពារសិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម។

លើសពីនេះទៅទៀត បងស្រីបានឲ្យដឹងទៀតថា សិទ្ធិធំៗទាំងបួននេះ គឺមិនសំដៅលើកុមារណាមួយទេ គឺម្នាក់ៗមានសិទ្ធិស្មើគ្នា ទោះបីកើតមកមានលក្ខណៈខុសប្លែកពីគ្នា មិនថាកូនអ្នកមានកូនអ្នកក្របក្នុងឋានៈណាក៏ដោយក៏យើងមានជីវិតដូចគ្នាមានសិទ្ធិស្មើគ្នា។

កុមារទាំងនោះមកពី៩តំបន់ក្នុងខេត្តកំពង់ចាមរួមមាន៖ ភូមិតាណោង, បឹងស្នាយ,អណ្តូងច្រុះ,ស្រឡៅ,រលៀក, ភូមិថ្មី, ទន្លេបិទ, និងមណ្ឌលយុវជន មណ្ឌលយុវនារី។

នៅក្នុងកម្មវិធីបណ្ណាល័យរបស់ព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគកំពង់ចាមជារៀងរាល់សប្តាហ៍បានយកចិត្តទុកដាក់ទៅលើកុមារទាំងការរៀនសូត្រ ទាំងម្ហូបអាហារប្រចាំថ្ងៃរបស់ពួកគេ ជាពិសេសគឺភូមិតាណោង ភូមិបឹងស្នាយ, និងភូមិទន្លេបិទ ដែលខ្វះអាហារហូបចុក និងទាំងសម្ភារសិក្សា៕







កម្មវិធីបណ្ណាល័យរបស់ព្រះសហគមន៍កាតូលិកក្នុងភូមិភាគកំពង់ចាម។

សកម្មភាពកម្មវិធីទិវាសិទ្ធិកុមារអន្តរជាតិលើកទី៧០ ដែលមានក្មេងៗចូលរួម២០០នាក់។ រូបភាព៖ ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម





# ផាត់ ចាន់ណា៖ គូសសញ្ញាឈើឆ្កាង និងសូត្រផ្តាំដើម្បីកុំឱ្យខ្ញុំវង្វេងជំនឿ





ទោះបីការងារមមារញឹក ប៉ុន្តែការធិដ្ឋានដើម្បីរស់នៅជាមួយព្រះជាម្ចាស់ជាកិច្ចការមួយសំខាន់របស់គ្រីស្តបរិស័ទ ទោះបីទៅដល់ទីណាក៏ដោយ ។ ការបង្ហាញសកម្មភាពនានាក្នុងសង្គមជាទង្វើមួយដែលគ្រីស្តបរិស័ទត្រូវតែធ្វើ ។ យុវជនផាត់ ចាន់ណា មកពីកំពង់ធំ រស់នៅនិងធ្វើការងារនៅភ្នំពេញ ជាច្រើនឆ្នាំបានឲ្យដឹងថាមុនពេលកិច្ចការងារណាមួយ គាត់តែងតែឧទ្ទិសការងារនោះជាមួយព្រះយេស៊ូជានិច្ច ។

ដោយ៖ រឿន ស្រីម៉ាច

ផាត់ ចាន់ណា ជាយុវជនមកពីព្រះសហគមន៍កំពង់រទេះនៃខេត្តកំពង់ធំក្នុងគ្រួសារជាពុទ្ធបរិស័ទដែលមានបងប្អូនប្រុសស្រី៨នាក់។ បច្ចុប្បន្នរូបគាត់កំពុងបម្រើការងារនៅក្នុងទីក្រុងភ្នំពេញ បន្ទាប់ពីរៀនចប់ដោយមានការឧបត្ថម្ភពីព្រះសហគមន៍។

កម្លោះវ័យ២៥ឆ្នាំរូបនេះបន្តថា៖«ចិត្តនិងបេះដូងខ្ញុំបានប្រគល់ឱ្យព្រះយេស៊ូគ្រីស្តចាប់តាំងពីពេលដែលខ្ញុំសម្រេចចិត្តទទួលអគ្គសញ្ញាជ្រមុជទឹក។ ព្រោះអ្វីៗ ខ្ញុំអាចធ្វើតាមគ្រួសារបាន តែចំពោះជំនឿគឺត្រូវធ្វើតាមបេះដូងឬចិត្តខ្លួនឯង ព្រោះព្រះយេស៊ូបានត្រាស់ហៅខ្ញុំឱ្យឃើញពន្លឺនៃសេចក្តីស្រលាញ់ចំពោះមនុស្សនៅជុំវិញខ្លួន»។

យុវជនរូបនេះទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១៣នៅព្រះវិហារគង្វាលសប្បុរស( កំពង់រទេះ) ខេត្តកំពង់ធំរួមជាមួយបេក្ខជនផ្សេងទៀតបន្ទាប់ពីទទួលរៀនអប់រំឈ្វេងយល់ជំនឿអស់រយៈពេល៣ឆ្នាំរួចមក។

ចាន់ណាបានឱ្យដឹងថា ក្រុមគ្រួសាររបស់គាត់មិនដែលរើសអើងសាសនានោះឡើយ ហើយរាល់ទង្វើរបស់ព្រះសហគមន៍កាតូលិកធ្វើនៅ ក្នុងសង្គមគឺជាទង្វើមួយដែលផ្តល់ប្រយោជន៍ដល់ប្រជាជនក្រីក្រ ចាស់ជរា ជួយកុមារកំព្រាឲ្យទទួលបានការសិក្សារៀនសូត្រ។

ចាន់ណា៖ «ខ្ញុំបានរៀនច្រើនពីព្រះសហគមន៍កាតូលិក ទាំងសេចក្តីស្រលាញ់ ការបន្ទាបខ្លួន ការលើកលែងទោស ការចេះលះបង់ពេលវេលាផ្ទាល់ខ្លួនសម្រាប់អ្នកដទៃ និងជាមនុស្សចេះគិតពិចារណាបានច្រើនជាងមុន ត្បិតកាលពីមុនខ្ញុំជាមនុស្សគិតតែអំពីប្រយោជន៍ផ្ទាល់ខ្លួន។ ហេតុនេះខ្ញុំចង់អរគុណព្រះសហគមន៍ដែលបង្រៀនឱ្យខ្ញុំចេះលេងហ្គីតា ចេះស្រលាញ់ក្មេងៗ អ្នកក្រីក្រ និងបញ្ជូនឱ្យខ្ញុំរៀនជំនាញមួយយ៉ាងត្រឹមត្រូវ ដើម្បីជាស្ពាននៅថ្ងៃអនាគត»។

ចាន់ណានិយាយទៀតថា សព្វថ្ងៃដោយសារតែភាពមមាញឹកជាមួយនឹងការងារ ហេតុនេះមិនសូវមានពេលសម្រាប់ទៅចូលរួមថ្វាយអភិបូជានៅថ្ងៃអាទិត្យឡើយ គឺយូរៗម្តងទើបបានចូលរួម ប៉ុន្តែគាត់នៅតែអធិដ្ឋាន ព្យាយាមមកព្រះវិហារ។

ចាន់ណា៖ «តែទោះជាយ៉ាងនេះក្តី ក៏ខ្ញុំមិនដែលភ្លេចព្រះជាម្ចាស់ តាមរយៈការអធិដ្ឋាន មើលព្រះគម្ពីរខ្លះៗ បន្ទាប់ពីម៉ោងសម្រាក។ ជាពិសេសគឺមុនពេលចាប់ផ្តើមធ្វើអ្វីមួយខ្ញុំតែងតែដោយព្រះនាមព្រះយេស៊ូ និងសូត្រផ្តាំតាមតែអាចធ្វើទៅបាន ព្រោះនេះជាផ្លូវមួយដ៏ល្អបំផុតដើម្បីកុំឱ្យខ្ញុំវង្វេងជំនឿ»។


ផាត់ ចាន់ណា កំពុងហាត់សមភ្លេង។ រូបភាព៖ សហការី

បើនិយាយអំពីការលំបាកក្នុងការផ្លាស់ប្តូរជំនឿវិញ យុវជនរូបនេះ បានឱ្យដឹងបន្ថែមថា មានតែមនុស្សមួយចំនួនដែលមិនបានស្គាល់ច្បាស់អំពីសាសនាគ្រីស្តនិកាយកាតូលិក គឺតែងតែសើច យំ មើលងាយ និង និយាយមិនល្អដាក់រូបគាត់ ដូចជាមិត្តរួមថ្នាក់ អ្នកជិតខាង និង បងប្អូនសាច់ឆ្ងាយជាដើម។

ចាន់ណា ពោលថា៖ «វាពិបាកពន្យល់ឱ្យនរណាម្នាក់មកស្ម័គ្រជឿដោយផ្ទុយពីគំនិតរបស់គេ។ ហេតុនេះមានតែពេលវេលានិងទង្វើល្អរបស់ខ្ញុំទើបអាចឆ្លើយបានថាអ្វីជាអ្វី»។

តាមបទពិសោធរបស់ខ្លួនចាន់ណាបានបង្ហាញថា ជំនឿមិនមែនបញ្ចប់ត្រឹមថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹកប៉ុណ្ណោះទេ គឺពេញមួយជីវិត។«ទោះបីពេលខ្លះខ្ញុំបាត់ជំនឿតិចៗ តែសំឡេងព្រះជាម្ចាស់និងរូបឈើឆ្កាងនៅជាប់ក្នុងចិត្តខ្ញុំជានិច្ច។ ខ្ញុំមិនដែលភ័យខ្លាចអំពីរឿងបាបនិងបុណ្យព្រោះព្រះជាម្ចាស់យេស៊ូគ្រីស្ត គឺជាអ្វីៗគ្រប់យ៉ាងក្នុងជីវិតខ្ញុំ។ នៅពេលខ្ញុំមានកំហុសគឺអាចកែប្រែបានតាមរយៈអគ្គសញ្ញាលើកលែងទោស»។

សព្វថ្ងៃ គ្រួសាររបស់ចាន់ណា មានសមាជិកចំនួន៣នាក់ក្នុងចំណោម៦នាក់ ជាគ្រីស្តបរិស័ទ។ លើសពីនេះក៏មានម្តាយមីង របស់គាត់ ដែលកំពុងរៀនអប់រំជំនឿផងដែរ។

យុវជនរូបនេះ ធ្លាប់ជាមនុស្សសកម្មនិងកិច្ចការព្រះវិហារជាខ្លាំង គឺជាអ្នកលេងហ្គីតាសម្រាប់ក្រុមចម្រៀងនៅថ្ងៃអាទិត្យ ជាអ្នកបម្រើអាសនៈ ជាគ្រូអប់រំជំនឿ ជាប្រធានយុវជន និងធ្វើកិច្ចការជាច្រើនទៀតដោយការស្ម័គ្រចិត្តក្នុងព្រះសហគមន៍កំពង់រទេះ។

ចាន់ណាបន្ថែមថា៖«សព្វថ្ងៃសំឡេងយុវជនកម្ពុជាក្នុងព្រះសហគមន៍ គឺកាន់តែខ្សោយទៅៗ ហេតុនេះទាំងខ្ញុំទាំងយុវជននិងប្អូនៗផ្សេងៗទៀតគួរតែក្រោកឡើងហ៊ានប្រកាសដំណឹងល្អ និងធ្វើជាសសរដ៏រឹងមាំសម្រាប់ព្រះសហគមន៍និងសង្គមនៅថ្ងៃអនាគត»៕

# គណៈកម្មការពលករភូមិភាគភ្នំពេញ ជួយឱ្យកម្មករកម្មការិនីចេះរួមសាមគ្គីគ្នា

*ដោយៈ លី សុវណ្ណា*

គណៈកម្មការពលករនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីបោះជំរំ សម្រាប់យុវកម្មករ ក្រោមប្រធានបទ «សាមគ្គីភាព និងភាពរុងរឿង» រយៈពេលបីថ្ងៃពីថ្ងៃទី ១៣-១៥ ខែឧសភា ឆ្នាំ២០១៩ នៅលើទឹកដីអង្គរខេត្តសៀមរាប ដែលមានយុវកម្មករ កម្មការិនី ចំនួន២៤នាក់ មកពីរោងចក្រមួយចំនួននៅតំបន់ ទួលពង្រ ក្នុងសង្កាត់ចោមចៅ រោងចក្រដំបូលខៀវ និងកាណាឌីយ៉ា។

តាមកញ្ញា ម៉ៅ ស្រីកែវ សមាជិកគណៈកម្មការពលករនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបរាប់ថា គោលដៅសំខាន់ក្នុងកម្មវិធីបោះជំរំនេះ គឺជួយឲ្យយុវកម្មករ កម្មការិនី បានស្គាល់គ្នា ចេះសាមគ្គីគ្នា យកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក។ ជាពិសេសនាំឲ្យគេបានយល់ និងស្គាល់នូវមរតកវប្បធម៌ដែលដូនតាបានបន្សល់ទុកមកគឺប្រាសាទអង្គរវត្ត និងប្រាសាទនានាដទៃទៀត មានសំបូរព្រៃគុកជាដើម និងភូមិវប្បធម៌ ដើម្បីឲ្យគេបានយល់ពីភាពរុងរឿងនៃវប្បធម៌ជាតិយើង។



សមាជិកអ្នកចូលរួមក្នុងកម្មវិធីបោះជំរំសម្រាប់យុវកម្មករក្រោមប្រធានបទ «សាមគ្គីភាព និងភាពរុងរឿង» *រូបភាពៈ សហការី*

កញ្ញាស្រីកែវបន្តថា ការរួមសាមគ្គីគ្នា និងចេះជួយគ្នាទៅវិញទៅមក គឺសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់កម្មករ ព្រោះថា នៅកន្លែងធ្វើការបើកម្មករចេះរួមសាមគ្គីគ្នា សហការគ្នា ជួយគ្នាដូចបងប្អូន កិច្ចការអ្វីក៏ងាយនឹងទទួលជោគជ័យដែរ។ ស្រីកែវ៖ «យើងមានល្បែងកំសាន្តរិះគិត ដើម្បីឲ្យគេបានយល់កាន់តែច្បាស់ថែមទៀត អំពីសាមគ្គីភាព និងការសហការក្នុងកិច្ចការជាក្រុម»។ ក្នុងនោះការស្នាក់នៅគឺ គ្រប់គ្នាត្រូវគេងក្នុងតង់ម្នាក់មួយ ជួយគ្នារៀបចំតង់ និងកិច្ចការផ្សេងទៀត។

យុវជន រ៉ា អាយុ២១ ឆ្នាំបានឲ្យដឹងថា គាត់សប្បាយរីករាយ ដោយបានដើរកម្សាន្តជុំគ្នា ទៅកន្លែងកម្សាន្តដ៏ល្បីនៅកម្ពុជា ដែលផ្តល់អារម្មណ៍ថ្មី ផ្តល់ទាំងចំណេះដឹង និងបានទាំងកម្សាន្តដែរ។ រ៉ា៖ «នេះជាលើកទីមួយដែលបានមកសៀមរាបនេះ ខ្ញុំសប្បាយចិត្តជាពិសេសបានឃើញអង្គរវត្តជាអ្វីដែលចង់ឃើញយូរណាស់ហើយ ខ្ញុំរំភើបចិត្តណាស់ពេលដែលឃើញប្រាសាទជាច្រើននោះ»។

ចំណែក សេងសារិត អាយុ ២៧ឆ្នាំ ធ្វើការក្រុមហ៊ុនផ្នែកអគ្គិសនី មានស្រុកកំណើតនៅខេត្តស្វាយរៀង មានចំណាប់អារម្មណ៍ថា ក្នុងកម្មវិធីបោះជំរំនេះ ពិតជាសប្បាយរីករាយដោយបានជួបជុំមិត្តភក្តិទាំងថ្មីនិងចាស់ មានទទួលចំណេះដឹងថ្មីដែរ។ ក្នុងកម្មវិធីយុវកម្មករយើងចេះជួយគ្នា សហការគ្នាដោយរៀបតង់ជាមួយគ្នា និងកិច្ចការផ្សេងៗទៀតក្នុងកម្មវិធី។



*កម្មករចេះរួមសាមគ្គីគ្នា សហការគ្នា ជួយគ្នាដូចបងប្អូន ក្នុងកិច្ចការផ្សេងៗ។* *រូបភាពៈ សហការី*

> យើងមានល្បែងកំសាន្តរិះគិត ដើម្បីឲ្យគេបានយល់កាន់តែច្បាស់ថែមទៀត អំពីសាមគ្គីភាព និងការសហការក្នុងកិច្ចការជាក្រុម ”

ជាមួយគ្នានេះយុវនារី ហួន អ៊ីម៉ា អាយុ ២០ឆ្នាំ ជាកម្មការិនី មកពីខេត្តកំពង់ស្ពឺ បាននិយាយថា៖ «ខ្ញុំសូមអរគុណដល់គណៈកម្មការពលករ ដែលបានជួយឲ្យយើងបានស្គាល់វប្បធម៌ជាតិយើង និងកម្មករទាំងអស់ចេះសាមគ្គីគ្នា មិនរើសអើង ចេះចែករំលែកគ្នា»។

គណៈកម្មការពលករនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បង្កើតឡើងក្នុងឆ្នាំ២០០៧ ក្នុងបេសកកម្មរួមដំណើរជាមួយកម្មករ ជួយគេឲ្យយល់ពីសិទ្ធិការងារ អំពីបំណិនជីវិត ការថែរទាំសុខភាព ជួយគេឲ្យចេះក្រោកឈរដោយខ្លួនឯងជាដើម។

ការបោះជំរំសម្រាប់យុវកម្មករនេះ បានប្រព្រឹត្តទៅជាលើកទី២ ដែលលើកដំបូងនៅខេត្តព្រះសីហនុ។ នេះបើតាមការបញ្ជាក់របស់កញ្ញាម៉ៅ ស្រីកែវ។ ស្រីកែវបន្តថា ក្រៅពីកម្មវិធីបោះជំរំរួមគ្នារបស់កម្មករ គណៈកម្មការពលករភូមិភាគភ្នំពេញក៏មានកម្មវិធីផ្សេងទៀតជាមួយកម្មករផងដែរដូចជា៖ មណ្ឌលយុវពលករ ដែលមានបន្ទប់ជួលសម្រាប់កម្មករក្នុងតម្លៃសមរម្យ, មហោស្រពសិល្បៈពលកររួមគ្នា, ជួបជុំកម្មករកម្មការិនី, កម្មវិធីបង្រៀនអនក្ខរកម្មដល់កម្មករកម្មការិនី, ជំនួបទិវាពលកម្មអន្តរជាតិ ១ ឧសភា, កម្មវិធីអធិដ្ឋានរួមគ្នា, សង្ខេបព័ត៌មាន, មានបណ្ណាល័យសម្រាប់កម្មករកម្មការិនី និងកូនៗរបស់គេអានសៀវភៅ, ផ្សព្វផ្សាយឯកសារសុខភាពកម្មករជាដើម៕





# វប្បធម៌ និងភាសាចិន នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន



**គ្រួសារកូនចៅចិន ឬក៏ជនជាតិខ្មែរដែលមានជាប់សែស្រឡាយចិន មានកាន់តែច្រើននៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ។ ការរស់នៅដោយអនុវត្តតាមវប្បធម៌ចិនក៏មានការពេញនិយម រីឯការសិក្សារៀនសូត្រភាសាចិនរបស់កូនខ្មែរជំនាន់នេះក៏មានការកើនឡើងផងដែរ។**

*ដោយៈ ផល សុផានិត*

ក្រៅអំពីការប្រារព្ធពិធីបុណ្យចូលឆ្នាំ ពិធីសែនលោកខែដូចនឹងប្រទេសចិន ការរៀបចំពិធីមង្គលការ និងពិធីតាមបែបសាសនាដទៃទៀតរបស់ចិន ក៏ទទួលបានការពេញនិយមខ្លាំងណាស់ដែរនៅក្នុងប្រទេសកម្ពុជា។

លោក ញ៉ៀប សុផល ហៅ វង្សម៉េង ជាសមាជិកម្នាក់របស់ត្រកូលអ៊ឹងនៅក្នុងប្រទេសកម្ពុជា និងជាប្រធានក្រុមម៉ុងសាយទី១ នៅរាជធានីភ្នំពេញ ក៏បានអះអាងដែរថា គ្រាន់តែរបបកម្ពុជាប្រជាធិបតេយ្យបញ្ចប់ទៅមិនបានប៉ុន្មានផង គ្រួសាររបស់លោកក៏បានរៀបចំបង្កើតក្រុមម៉ុងសាយឡើងវិញតែម្តង។

ការបង្កើតឡើងវិញនៅក្នុងឆ្នាំ ១៩៩៣ សម្របតាមបែបប្រពៃណីក្នុងរាជធានីភ្នំពេញ ពុំមែនជាកិច្ចការថ្មីថ្មោងរបស់ត្រកូលលោកនោះឡើយ។ គិតត្រឹមជំនាន់របស់លោកម៉េង ដូនតារបស់លោកបានមករស់នៅក្នុងប្រទេសកម្ពុជា៦ជំនាន់មកហើយ។

លោក ញ៉ៀប សុផល និយាយថា៖ «មួយថ្ងៃៗកាន់តែជឿនលឿនទៅ គេក៏ហៅក្រុមម៉ុងសាយទៅសម្តែងកាន់តែច្រើន សម្ពោធក៏គេហៅ ព្រោះជនជាតិចិនមកវិនិយោគច្រើនក្នុងប៉ុន្មានឆ្នាំនេះ កសិកម្មក៏មាន ការសាងសង់ វាគ្រប់ផ្នែក»។

បុរសជាសមាជិកត្រកូលអ៊ឹង បានបញ្ជាក់ទៀតថា បើតាមការអង្កេតរបស់លោកផ្ទាល់ មូលហេតុ សំខាន់ដែលធ្វើឱ្យវប្បធម៌ខ្មែរចិនងាយចុះសម្រុងគ្នា ដោយសារប្រទេសទាំងពីរ គឺកម្ពុជា និងចិន មានប្រវត្តិការទូតជាមួយគ្នាយូរលុងមកហើយ។ ពិធីបុណ្យប្រពៃណីចិនមួយចំនួនមានអត្ថន័យប្រហាក់ប្រហែលនឹងគ្នា។

លោក ញ៉ៀប សុផល និយាយថា៖ «បើខ្ញុំគិតវាមិនខុសគ្នាអីប៉ុន្មានទេ វាអាចរស់នៅចុះសម្រុងគ្នាបាន ប្រពៃណីខ្មែរ និងប្រពៃណីចិនដូចៗគ្នាទាំងអស់ បុណ្យអុំទូកចិនក៏មាន សែនផ្កាខ្មែរយើងភ្ជុំបិណ្ឌ គ្រាន់តែខុសតែថ្ងៃខែ»។

បុរសខាងលើយល់ឃើញថា បើគិតផ្តោតតែលើវប្បធម៌ ប្រពៃណីតែម្យ៉ាង ទោះបីកូនខ្មែរប្រកាន់ខ្ជាប់វប្បធម៌ខ្មែរ និងចិនដំណាលគ្នា ក៏ពុំផ្តល់ផលប៉ះពាល់អ្វីនោះទេ សំខាន់ការរស់នៅត្រូវមានសាមគ្គី យោគយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក ហើយឆ្ពោះទៅរកភាពរីកចម្រើនទាំងអស់គ្នា។

លោក ញ៉ៀប សុផល៖ «ធម្មតាទេការផ្លាស់ប្តូរវប្បធម៌គ្នាវាមិនថយក្រោយនោះទេ វាកាន់តែជឿនលឿន កាន់តែទៅមុខដូចគ្នា ការរកស៊ីផ្លាស់ប្តូរគ្នា ១០ ឬ២០ឆ្នាំទៅមុខទៀតវាកាន់តែរុងរឿងមែនទែន វាកាន់តែខ្លាំងមែនទែន»។

លោកសាស្ត្រាចារ្យ សំបូរ វណ្ណារ៉ា បង្រៀនផ្នែកប្រវត្តិសាស្ត្របានឲ្យដឹងថា កម្ពុជា និងចិនបានភ្ជាប់ទំនាក់ទំនងគ្នាតាំងពីសតវត្សទី៣ នៃគ.ស បន្ទាប់ពីមហាក្សត្រខ្មែរ ព្រះនាមហ្វាន់ជីមាន់ បង្កើតនូវកំពង់ផែអន្តរជាតិដើម្បីបើកទទួលធ្វើពាណិជ្ជកម្មជាមួយសាសន៍ដទៃ។ ពេលនោះហើយដែលលំហូនៃជនជាតិចិនបានមកដល់។

លោកសាស្ត្រាចារ្យបន្ថែមថា បច្ចុប្បន្នយើងមិនអាចនិយាយថា ប្រទេសចិនមានឥទ្ធិពលមកលើកម្ពុជាបានទេ។ លោក វណ្ណារ៉ា៖ «ពាក្យថាឥទ្ធិពលខ្ញុំមិនចង់ប្រើទេ ព្រោះថាយើងអន់ជាងគេ។ ខ្ញុំបាននិយាយហើយ យើងចង់បានគេ យើងក្រយើងឃ្លាន យើងត្រូវការគេឲ្យ។ ចឹងកាលណាគេឲ្យកាលណាយើងឆ្ងាញ់យើងទទួលយក នេះមិនមែនឥទ្ធិពលទេ។ ចឹងយើងមានទំនោរដោយខ្លួនឯង យើងចង់បានគេដោយខ្លួនឯង ចឹងត្រូវគិតឡើងវិញមិនមែនគេខ្លាំងដោយសារយើងទៅរកគេនោះទេ។ បើគេខ្លាំងយើងទៅរកគេ បានគេមានឥទ្ធិពល»។

លោកសាស្ត្រាចារ្យបន្ថែមទៀតថា៖ «សម័យនេះ សតវត្សទី២១ហើយ មិនចង់ក៏គេមកដែរ នេះសម័យទំនាក់ទំនងសកលភាវូបពាណិជ្ជកម្ម ដូច្នេះយើងមាំខ្លួនឯងអត់ យើងខ្លាំងអត់?»

ទន្ទឹមនឹងការរីកសាយនៃវប្បធម៌ប្រពៃណីចិនកាន់តែខ្លាំងនៅក្នុងប្រទេសកម្ពុជា ចំនួននៃសាលារៀនភាសាចិនក៏មានច្រើនគួរឱ្យកត់សម្គាល់ផងដែរ។ តើកូនខ្មែរសិក្សាភាសាចិនក្នុងគោលបំណងបែបណាខ្លះ?

កញ្ញា ហួយ មីង ជាសិស្សសិក្សាភាសាចិននៅសាលាមួយក្បែរផ្សារអូឡាំពិក បាននិយាយថា៖ «ម៉ាក់ថារៀនភាសាចិនរកការងារបានធ្វើ មានការងារច្រើន អាចឡើងទៅចិនជាមួយប៉ាយកអីវ៉ាន់»។

កុមារា លឹម សុខសំណាងបាននិយាយថា៖ «រៀនចិនរៀនយូរទៅមានអនាគត។ ម៉ាក់ខ្ញុំគាត់កាត់ចិន តែប៉ាមិនកាត់ទេ។ បានខ្ញុំសម្រេចចិត្តទៅរៀនចិន ដើម្បីគិតថា ពេលខ្ញុំធំឡើងខ្ញុំអាចបកប្រែឱ្យគេបាន»។

អតីតសិស្សសាលាភាសាចិនម្នាក់ឈ្មោះថា លី ឆាយ និយាយថា «ភាសានិងអក្សរចិនគឺត្រូវចំណាំអក្សរតែភាសាខ្មែររៀនប្រកប។ បើយើងចេះភាសាចិន យើងអាចរកប្រាក់ខែបានច្រើនជាងអត់ចេះភាសាចិន» ។

ថ្វីត្បិតតែការចេះភាសាចិនជាចំណែកមួយដែលគ្រួសារខ្មែរមួយចំនួនបានគិតថា ជាការជួយរុញច្រានជីវិតរបស់កូនៗរបស់ពួកគាត់ ឆ្ពោះទៅអនាគតល្អប្រសើរ តែសាស្ត្រាចារ្យដែលបង្រៀននៅសាលាអន្តរជាតិមួយចំនួនបានយល់ឃើញថា **ភាសាបរទេសគ្រាន់តែជាភាសាយាន តែបើបំភ្លេចចោលភាសាជាតិក៏មិនមែនជាជំហានត្រឹមត្រូវនោះដែរ។**

សាស្ត្រាចារ្យ សួន សុភា ជាមន្ត្រីបម្រើការងារនៅវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិតសភាកម្ពុជាបានពោលថា បើសិនជាយើងមិនបានរៀនភាសាខ្មែរយើងឱ្យបានជ្រាលជ្រៅនោះទេ ដែលយើងហៅថា ភាសាជាតិតំណាងឱ្យខ្មែរយើង ជាអត្តសញ្ញាណជាតិខ្មែរយើងនោះទេ ថ្ងៃក្រោយយើងនឹងបាត់បង់ហើយ។

លោកបន្ថែមថា យើងឃើញថាកូនខ្មែរយើងបច្ចុប្បន្ននេះ មិនពេញនិយមអក្សរសាស្ត្រជាតិយើងនោះទេ ចឹងវាជាការសោកស្តាយមួយដែរ ប្រសិនបើយើងមិនប្រយ័ត្នទេ វាបាត់អត្តសញ្ញាណរបស់យើងជាកូនខ្មែរ ហើយកូនខ្មែរភាគច្រើននឹងបាត់ស្នេហាជាតិ ស្នេហាវប្បធម៌ ដែលធ្វើឱ្យយើងក្លាយទៅជាកូនកាត់ ឬកាឡៃ។

ទំនាក់ទំនងខ្មែរចិនមិនមែនជារឿងថ្មីនោះទេកំណត់ត្រាប្រវត្តិសាស្ត្រជាច្រើនបានបញ្ជាក់ច្បាស់ពីទំនាក់ទំនងការទូត និងទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ជាក់ស្តែងការទាក់ទងផ្នែកការទូតរវាង អាណាចក្រខ្មែរ និងចិន នៅសម័យបុរាណ បេសកជនចិន លោកជីវតាក្វាន់ បានធ្វើការកត់ត្រាអំពីប្រពៃណី អ្នកស្រុកចេនឡា តម្កល់ទុកក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ខ្លួន ក្នុងរាជ្យវង្ស ម៉ុងហ្គោលជាដើម៕



*ការរៀបចំសែនព្រេនបែបចិន។* *រូបភាពៈ សហការី*



*សាលាបង្រៀនភាសាចិន ដែលបើកបង្រៀនក្នុងរាជធានីភ្នំពេញ។*

# មណ្ឌលសិល្បៈ និងចម្លាក់វត្តភ្នំ ជួយដល់ស្ត្រី និងជនមានពិការភាព

**មណ្ឌលសិល្បៈ និងចម្លាក់វត្តភ្នំ ដែលស្ថិតនៅក្នុងបរិវេណ រមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ បានដើរតួនាទីមួយក្នុងការបង្ហាញនូវសិល្បៈ វប្បធម៌ ប្រពៃណីជាតិដល់ភ្ញៀវទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ។ ក្នុងនោះមណ្ឌលនេះ ក៏ជួយដល់ជីវភាពរបស់ស្ត្រី និងជនមានពិការភាពឲ្យទទួលបានប្រាក់កម្រៃសម្រាប់គ្រួសារផងដែរ។**



*កន្លែងលក់វត្ថុអនុស្សាវរីយ៍ និងតាំងបង្ហាញផលិតផលខ្មែរនៅមណ្ឌលសិល្បៈ និងចម្លាក់វត្តភ្នំ។*

*ដោយ៖ ផល សុផានិត*

វត្តភ្នំត្រូវបានគេស្គាល់ជាទូទៅថា ជាចំណុចកណ្ដាលនៃរាជធានី របស់ប្រទេសកម្ពុជា។ ប្រជាពលរដ្ឋជាអ្នករស់នៅក្នុងរាជធានីភ្នំពេញ និងប្រជាជនទាំងអស់ ពិតជាបានស្គាល់ទីនោះ ដែលជាតំបន់រមណីដ្ឋានទេសចរណ៍ វប្បធម៌ និងប្រវត្តិសាស្ត្រ ព្រមទាំងជាទីសក្ការៈផងដែរនោះ។

នៅក្បែរទីរមណីយដ្ឋាន វត្តភ្នំ មានទីតាំងមួយ ជាអាគារប្រណិតមួយកំពុងដាក់តាំងជាច្រើននូវសិល្បៈ វប្បធម៌របស់ខ្មែរ និងវត្ថុអនុស្សាវរីយ៍ ដែលសុទ្ធសឹងជាផលិតផលរបស់ខ្មែរ សម្រាប់ជូនភ្ញៀវទេសចរណ៍។

ចាប់ពីកកើតឡើងក្នុងឆ្នាំ២០១៨ មកដល់បច្ចុប្បន្ននេះ មជ្ឈមណ្ឌលសិល្បៈ និងចម្លាក់វត្តភ្នំ បានប្រមូលទិញផលិតផលដែលផលិតឡើងដោយក្រុមស្ត្រី និងជនមានពិការភាព ដែលកំពុងតែរស់នៅតាមបណ្ដាសហគមន៍នានាក្នុងប្រទេសកម្ពុជា។

អ្នកស្រីចិន្ដាជាអ្នកលក់ផលិតផលឲ្យដឹងថា នៅទីនេះមានផលិតផលច្រើន ជាសម្លៀកបំពាក់ដែលផលិតពីហូលផាមួងខ្មែរ ដែលមានគុណភាពខ្ពស់ និងមានការកែច្នៃម៉ូតពីស្ត្រីខ្មែរពិតៗ។

អ្នកស្រី ចិន្តា៖ «នៅទីនេះមានផលិតផលច្រើន ហូលផាមួង និងសម្លៀកបំពាក់ដែលច្នៃពីហូលផាមួងខ្មែរពិតៗ និងច្នៃចេញជាម៉ូតប្លែក តាមបែបបច្ចិមប្រទេស ហើយក៏មានផលិតផលផ្សេងៗទៀតផងដែរ។ ផលិតផលទាំងអស់នោះ យកមកពីសហគមន៍ផ្សេងៗគ្នា មានទាំងសិប្បកម្ម ចម្លាក់ផ្សេងៗមកពីតាមបណ្ដាខេត្តខុសៗគ្នា»។

លោក ជំទាវ ញ៉ែម មរកត ប្រធានមជ្ឈមណ្ឌលសិល្បៈ និងចម្លាក់វត្តភ្នំ បានឲ្យដឹងថា៖ «ការដាក់តាំងនៅទីនេះ សុទ្ធតែជារបស់ស្ត្រី សហគ្រិននៅតាមសហគមន៍ និងជនមានពិការភាព ដែលលោកផលិតបាន ហើយយកមកដាក់នៅទីនេះ លក់និងបង្ហាញសម្រាប់ភ្ញៀវ»។

លោកជំទាវ ថា មជ្ឈមណ្ឌលនេះ ត្រូវការការគាំទ្រយ៉ាងសំខាន់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឲ្យវារស់រានឡើង ក្នុងគោលដៅគាំទ្រដល់អ្នកផលិត និងការដាក់បង្ហាញនូវវប្បធម៌របស់ខ្មែរយើង។

លោកជំទាវ មរកត៖ «មិនមែនជាការងាយស្រួលនោះទេ ត្រូវការទីកន្លែង ការគាំទ្រ ពីថ្នាក់ដឹកនាំ ក៏ដូចជាក្រុមគ្រួសារ ដើម្បីឱ្យកន្លែងមួយនេះក្លាយទៅជា កន្លែងមួយដែលបម្រើទៅនឹងវិស័យទេសចរណ៍ និងស្ត្រី ព្រមទាំងបងប្អូន ជាជនពិការផងដែរនោះ»។

លោកជំទាវ ប្រធានមជ្ឈមណ្ឌល បានឱ្យដឹងទៀតថា បច្ចុប្បន្នកន្លែងនេះ មានហាងលក់ផលិតផលខ្មែរជាង ២០ហាង ដែលហាងនីមួយៗបានយកទំនិញពីសហគមន៍នានាសម្រាប់ដាក់តាំងបង្ហាញលក់ ហើយមជ្ឈមណ្ឌលនេះ ក៏ទទួលបានការគាំទ្រ ពីភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ដែលបានចូលមកទស្សនានៅរមណីយដ្ឋានវត្តភ្នំនេះ៕

# ស្ថានភាពគ្រឿងស្រវឹងនៅក្នុងប្រទេសកម្ពុជា

**គ្រឿងស្រវឹងត្រូវបានគេទទួលស្គាល់ថា ជាផលិតផលសុរាដែលតែងឃើញប្រើប្រាស់នៅតាមទីសាធារណៈ និងកម្មវិធីជប់លៀងនានា។ ប្រជាពលរដ្ឋមួយចំនួនបានយល់ឃើញថា នៅក្នុងកម្មវិធីសប្បាយៗរបស់ពួកគាត់ បើខ្វះសុរាហាក់ដូចជាសោះកក្រោះ។ ម្យ៉ាងទៀត ការរាប់អានមិត្តភក្ដិក្ដី សុរាតែងយកមកដើម្បីស្វាគមន៍គ្នាទៅវិញទៅមក។ ក្នុងសង្គមកម្ពុជាមិនថាបុរស ឬស្ត្រីនោះទេ ការទទួលទានគ្រឿងស្រវឹងគឺមានសឹងតែគ្រប់គ្នា។ គ្រោះថ្នាក់ដែលកើតឡើងពីការទទួលទានគ្រឿងស្រវឹងក៏ស្ថិតនៅក្នុងកម្រិតមួយគួរព្រួយបារម្ភផងដែរ។**

*ដោយ៖ ផល សុផានិត*

ប្រទេសកម្ពុជាសព្វថ្ងៃ ហាក់ក្លាយជាទម្លាប់សម្រាប់មនុស្សទូទៅ ដែលនៅក្នុងកម្មវិធីសប្បាយៗ មិនថាអាពាហ៍ពិពាហ៍ ខួបកំណើត ពិធីបុណ្យផ្សេងៗដែលទាក់ទងទៅនឹងកម្មវិធីកម្សាន្ត ម្ចាស់កម្មវិធីតែងតែទទួលភ្ញៀវ ដោយគ្រឿងស្រវឹង។

ការផ្សាយពាណិជ្ជកម្មទៀតសោត រឹតតែមានការរិះគន់យ៉ាងចាស់ដៃពីសំណាក់មហាជនទូទៅនៅទូទាំងប្រទេស។ នៅតាមបណ្ដាស្ប៉តពាណិជ្ជកម្ម តែងតែនាំមុខភាគច្រើនដោយគ្រឿងស្រវឹងជាពិសេសស្រាបៀរ។ មិនថាតែក្នុងកញ្ចក់ទូរទស្សន៍នោះទេ តាមផ្លូវសំខាន់ៗមួយចំនួនធំ យើងសង្កេតឃើញមានផ្ទាំងប៉ាណូធំៗ អំពីពាណិជ្ជកម្មស្រាបៀរ។

តាមរបាយការណ៍ពីនាយកដ្ឋានសណ្ដាប់ធ្នាប់នៃក្រសួងមហាផ្ទៃ បានកំណត់ឃើញថា កត្តាគ្រោះថ្នាក់ចរាចរណ៍ដែលភាគច្រើន កើតមានក្នុងពេលយប់ គឺដោយសារគ្រឿងស្រវឹង។ ជម្លោះពាក្យសម្ដី ការបាញ់បោះមួយចំនួនក៏កើតចេញពី ការសេពគ្រឿងស្រវឹងដ៏ច្រើនលើសលប់ ធ្វើឲ្យបាត់បង់ម្ចាស់ការលើខ្លួនឯង។

អាជីវករលក់ដូរមួយរូប ស្ថិតនៅសង្កាត់ស្រះចក រាជធានីភ្នំពេញ លោក រិន រតនៈ មានវ័យជាង៦០ឆ្នាំ បានឲ្យដឹងថា គាត់មិនសូវចូលចិត្តទទួលទានគ្រឿងស្រវឹងទេ តែនៅពេលដែលគាត់រៀបចំអាពាហ៍ពិពាហ៍កូនប្រុសកាលពីពេលកន្លងទៅនេះ ក៏ទទួលស្វាគមន៍ភ្ញៀវកិត្តិយស ដោយស្រា និងស្រាបៀរដែរ។

លោក រិន រតនៈ និយាយថា៖ «បើសិនជាយើងគ្មានស្រាឬស្រាបៀរទេ កម្មវិធីនោះអត់សប្បាយទេ។ ហើយជាប្រពៃណីទំនៀមទំលាប់ខ្មែរយើង តាំងពីបុរាណមកថា បើការជប់លៀងចឹងមានទឹកក្រូច ស្រាបៀរនោះចឹងដើម្បីឲ្យបរិយាកាសវាសប្បាយរីករាយ»។

នៅក្នុងពិធីនោះ លោកត្រូវចំណាយប្រាក់អស់ប្រហែល ១៥០០ដុល្លា ទៅ២០០០ដុល្លា ទៅលើភេសជ្ជៈ ដើម្បីបង្កើនបរិយាកាសអ៊ូអរ។

លោក រិន រតនៈ៖ «បើអត់មានស្រានុះ ក៏គេមិនទៅចូលរួមដែរ ព្រោះថាការរាប់អានគ្នា វាត្រូវតែចូលចឹងហើយ។ តែគ្រាន់តែថា អត់មានបរិយាកាសនឹងវាស្ងាត់ វាអត់សប្បាយហ៊ឹកហ៊ាក់ចឹងទៅ។ តែចំណាងដៃបើតាមខ្ញុំមើលទៅ ការដែលគេរាប់អានយើងក៏គេមិនបន្ថយដែរ»។

ចំណែក លោក សុធារ៉ា និយាយថា គាត់មិនធ្លាប់ចូលរួមពិធីមង្គលណាមួយដោយគ្មានគ្រឿងស្រវឹងឡើយ ផ្ទុយទៅវិញបើពិធីណាគ្មានគ្រឿងស្រវឹងទេ ពិធីនោះហាក់មានបរិយាកាសសោះកក្រោះ ហើយនាំឲ្យកម្មវិធីឆាប់ចប់ទៅវិញ។

ចំណែកអ្នកនាង សុធីតាភរិយារបស់លោក សុធារ៉ា កត់សម្គាល់ឃើញថា ភ្ញៀវដែលចូលរួមពិធីមង្គលការរបស់អ្នកទាំងពីរប្រមាណ៩០% សុទ្ធតែទទួលទានគ្រឿងស្រវឹង។ អ្នកនាងបង្ហាញក្ដីបារម្ភពីសុខភាពភ្ញៀវ ញាតិមិត្ត និងអំពីសុខសុវត្ថិភាពក្នុងពេលធ្វើដំណើរត្រឡប់ទៅវិញ ខណៈដែលពួកគាត់ទទួលទានគ្រឿងស្រវឹងហើយបើកបរ។

អ្នកនាង សុធីតា៖ «អត់ចង់ឲ្យគាត់ញ៉ាំស្រាច្រើនដែរ ព្រោះវាប៉ះពាល់ដល់សុខភាព បញ្ហាសុវត្ថិភាពតាមផ្លូវ។ ជាតិនៃសុរានោះធ្វើឲ្យយើងបាត់បង់ស្មារតី នៅក្នុងការបើកបរ»។

ប្រធានមជ្ឈមណ្ឌលដើម្បីប្រជាពលរដ្ឋ លោក យឹម គឹមអេង បានយល់ឃើញថា ការកើនឡើងនៃការទទួលទាន គ្រឿងស្រវឹង នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ដោយសារការផ្សព្វផ្សាយច្រើន ដែលនាំឲ្យមានការយល់ច្រឡំ។ យុវវ័យចង់សាកល្បង ចំណែកមនុស្សចាស់ចង់រក្សាទំនាក់ទំនងតាមរយៈគ្រឿងស្រវឹង។

លោក យឹម គឹមអេង៖ «ប្រព័ន្ធផ្សព្វផ្សាយភាគច្រើន ផ្សព្វផ្សាយពីគ្រឿងស្រវឹង ប៉ុន្តែមិនបានផ្សាយអំពីគ្រឿងស្រវឹង ប៉ះពាល់ដល់អ្វីនោះទេ ដូចជាប៉ះពាល់ដល់សុខភាព មានជំងឺ ពាក់ព័ន្ធហិង្សា ពាក់ព័ន្ធគ្រោះថ្នាក់ចរាចរណ៍ជាដើម។ រឿងរ៉ាវទាំងអស់នោះមិនផ្សាយនោះទេ ទូរទស្សន៍ វិទ្យុ តិចណាស់ដែរលផ្សាយពីរឿងនេះ។ ការផ្សាយ( គ្រឿងស្រវឹង) ច្រើនមែនទែន»។

លោក យឹម គឹមអេង ថា៖ «យើងធ្វើច្បាប់មិនបានហាមមនុស្សមិនឲ្យផឹកនោះទេ តែដើម្បីកាត់បន្ថយហានិភ័យ ព្រោះមនុស្សម្នាក់ៗ ដឹងថាខ្លួនឯងផឹក អាចនឹងមានបញ្ហា។ នៅពេលដែលមានបញ្ហា ខ្លួនឯងពិសាទៀត មិនដឹងធ្វើម៉េចនោះទេ។ រឿងដែលសំខាន់បំផុតនោះគឺមិនចង់ឲ្យអ្នកពិសានោះ បើកបរបុកគេបុកឯង បង្កហិង្សាគ្រប់បែបយ៉ាង គឺយើងចង់ទប់ស្កាត់អំពើបែបហ្នឹង មិនមែនទប់ស្កាត់មនុស្សមិនឲ្យផឹកនោះទេ»។

តាមការសិក្សាមួយកាលពីឆ្នាំមុនរបស់ក្រសួងសុខាភិបាលឲ្យដឹងថា ពលរដ្ឋពេញវ័យ បុរស៧៣% ស្ត្រី២៣% បានទទួលទានគ្រឿងស្រវឹងរយៈពេល១២ខែ។ មតិពលរដ្ឋ ៧៥% គាំទ្រឲ្យរាជរដ្ឋាភិបាល តម្លើងពន្ធលើផលិតផលគ្រឿងស្រវឹង ហើយក៏ចង់ឲ្យរដ្ឋពន្លឿនច្បាប់ស្ដីពី ការគ្រប់គ្រងគ្រឿងស្រវឹងឲ្យបានឆាប់តាមដែលអាចធ្វើបាន។

តាមរបាយការណ៍ពីនាយកដ្ឋានសណ្ដាប់ធ្នាប់នៃក្រសួងមហាផ្ទៃ ឆ្នាំ២០១៨ បានបង្ហាញថា នៅឆ្នាំ២០១៨ កន្លងទៅនេះ ករណីគ្រោះថ្នាក់ចរាចរណ៍បានថយចុះប្រមាណ៧ភាគរយ ប្រៀបធៀបនឹងឆ្នាំ២០១៧ ក្នុងនោះចំនួនអ្នកស្លាប់បានថយចុះ១ភាគរយ ចំណែកឯចំនួនអ្នករបួសដោយគ្រោះថ្នាក់ចរាចរណ៍បានថយចុះ១៨ភាគ៕





# កិច្ចប្រជុំសហព័ន្ធព្រះគម្ពីរកាតូលិកនៅទីក្រុងរ៉ូម

*ដោយ៖ កប្បព្រឹក្ស*

ក្រោយពេលមានមហាសន្និបាតវ៉ាទីកង់ទី២ ព្រះសហគមន៍កាតូលិក បានផ្លាស់ប្ដូររបៀបថ្មីក្នុងការប្រតិបត្តិជំនឿរបស់ខ្លួន ជាពិសេសព្រះគម្ពីរត្រូវបានអនុញ្ញាតឲ្យបកប្រែជាភាសាតំបន់ឬប្រទេស។ សហព័ន្ធព្រះគម្ពីរកាតូលិកក៏ត្រូវបានបង្កើតឡើងដើម្បីជាជំនួយដល់អស់អ្នកដែលធ្វើការងារលើផ្នែកនេះ។

ថ្មីៗនេះ សហព័ន្ធនេះបានប្រារព្ធខួប៥០ឆ្នាំរបស់ខ្លួន ដែលបានរៀបចំឡើងនៅទីក្រុងរ៉ូម កាលពីថ្ងៃទី២៤-២៦ មេសាកន្លងទៅ។ លោក កាន់ ប៊ុយ ជាសមាជិកគណៈកម្មការប្រតិបត្តិនៃការិយាល័យព្រះគម្ពីរកាតូលិក និងជាតំណាងព្រះសហគមន៍នៅកម្ពុជាបានចូលរួមកម្មវិធីនេះ។ លោកបានឲ្យដឹងថា៖ «យើងឃើញថាព្រះគម្ពីរបង្កប់ដោយទេវវិទ្យាអស្ចារ្យដែលនាំឲ្យយើងយកមកដើម្បីបកស្រាយ និងយល់អំពីជីវភាពរបស់យើង ជាពិសេសក្នុងពិធីបុណ្យដែរ»។

នៅក្នុងសមាជជាអន្តរជាតិ របស់សហព័ន្ធគម្ពីរកាតូលិកដែលមានសមាជិកចូលរួមចំនួន ២០០នាក់ មកពី៦៨ប្រទេសនៅគ្រប់ទ្វីប មានប្រធានបទរួមគឺ «ព្រះគម្ពីរនិងជីវិត»។ ក្នុងនោះដែរ គេបានបែងចែកជាប្រធានបទតូចៗជាច្រើន ដូចជា ព្រះគម្ពីរ និងការអប់រំជំនឿ យុវជន-គ្រួសារ និងព្រះគម្ពីរ ព្រះគម្ពីរ និងបច្ចេកវិទ្យា ដើម្បីរិះគិតបន្ថែមអំពីគម្រោងទៅអនាគត។



*លោក កាន់ ប៊ុយ បានសម្ដែងការគួរសមជាមួយនឹងសម្ដេច ប៉ាប ហ្វ្រង់ស៊ីស។ រូបភាព៖ សហការី*

លោកប៊ុយបន្ថែមថា៖ «នៅក្នុងកិច្ចប្រជុំនោះ ខ្ញុំចាប់អារម្មណ៍ និងចង់ផ្ញើពេលអនាគត គឺអំពីការនាំព្រះគម្ពីរតាមរបៀបថ្មី គឺបច្ចេកវិទ្យាទំនើប ដោយសារយើងឥឡូវ ហួសពីការបោះពុម្ពសៀវភៅ យើងមានវេបសាយដែលគ្រប់គ្នាអាចទទួលអត្ថប្រយោជន៍ទាំងការអាន មើល និងស្ដាប់។ ( យើង )អាចធ្វើមេរៀនដើម្បីបង្រៀនគេ តាមក្រុមតូចៗដើម្បីណែនាំគេបន្ថែម»។

លោកបានបន្តថា ក្នុងកិច្ចប្រជុំរយៈពេល២ថ្ងៃកន្លះនេះ ប្រទេសនីមួយៗមានរបាយការណ៍មួយចំនួនពីអ្វីដែលពួកគេបានរៀបចំធ្វើក្នុងរយៈពេល៥០ឆ្នាំមកហើយនេះ។

លោកប៊ុយ រំលឹកថា ព្រះសហគមន៍នៅកម្ពុជាជាសមាជិកនៃសហព័ន្ធនេះ តាំងពីឆ្នាំ ១៩៧៣ ហើយមានសកម្មភាពមួយចំនួនគឺការបកប្រែគម្ពីរដោយលោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៏ ជាមួយក្រុមជំនុំប្រកាសដំណឹងល្អ ឬអន្តរនិកាយ។ ប៉ុន្តែដោយសារសង្គ្រាម យើងបានផ្អាកមួយរយៈធំ បន្ទាប់មកត្រូវបានធ្វើឡើងវិញក្នុងទសវត្សរ៍ឆ្នាំ៩០។ រួមជាមួយគ្នានោះ លោកបូជាចារ្យអង្គនេះក៏ធ្វើការងារបោះពុម្ពសៀវភៅពិធីបុណ្យផ្សេងៗ សៀវភៅអប់រំជំនឿ ដែលយើងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។



*លោក កាន់ ប៊ុយ (កណ្ដាល) ជាសមាជិកគណៈកម្មការប្រតិបត្តិនៃការិយាល័យព្រះគម្ពីរកាតូលិក និងជាតំណាងព្រះសហគមន៍នៅកម្ពុជាបានចូលរួមកម្មវិធី។ រូបភាព៖ សហការី*

នៅក្នុងកិច្ចប្រជុំនេះ ក៏មានវត្តមានរបស់សម្ដេច ប៉ាប ហ្វ្រង់ស៊ីស្កូ នៅថ្ងៃទី២៦ មេសាផងដែរ។ សម្ដេចប៉ាបមានបន្ទូលសូមឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់អានព្រះគម្ពីរ។ លោកកាន់ប៊ុយឲ្យដឹងយ៉ាងដូច្នេះ «សម្ដេចប៉ាបមានបន្ទូលថា មិនចាំបាច់ស្វែងរកបុគ្គលណាពូកែ ឬមានខួរក្បាលល្អ ពូកែគិត ពូកែនិយាយ គឺមិនចាំបាច់ទេ។ តែយើងផ្ដោត និងយកចិត្តទុកដាក់ដោយអានគម្ពីរ និងទាញយកប្រភពថាមពលពីគម្ពីរ ជួយក្នុងដំណើរជីវិតរបស់យើង។ សម្ដេចប៉ាបក៏បានគាំទ្រលើសកម្មភាពទាំងឡាយស្ដីអំពីព្រះគម្ពីរនេះដែរ»។

លោកកាន់ ប៊ុយ បន្ថែមថា នៅក្នុងគណៈកម្មការព្រះគម្ពីរកាតូលិកកម្ពុជា គឺកំពុងតែយកចិត្តទុកដាក់កែសម្រួល សិក្ខាសាលាព្រះគម្ពីរសម្រាប់ពន្លកថ្មី និងចង់បន្តការអានព្រះគម្ពីរនៅក្នុងក្រុមតូចៗ។ យើងមានគម្រោងបោះពុម្ពកូនសៀវភៅអំពីរបៀបអាន និងមានសេចក្ដីពន្យល់អំពីព្រះគម្ពីរ ដែលនាំឲ្យអ្នកអានយល់បានច្រើនអំពីគម្ពីរ។ យើងត្រូវការបង្កើតគេហទំព័រវេបសាយមួយដើម្បីរក្សាទុកព័ត៌មាន និងបង្កើតមេរៀនដើម្បីពន្យល់ និងបង្រៀន និងមានការរៀបចំបោះពុម្ពគម្ពីរលើកទី២ដោយប្រើប្រាស់ពាក្យរបស់ព្រះសហគមន៍៕

## សហព័ន្ធព្រះគម្ពីរកាតូលិក (CBF - Catholic Biblical Federation)

ជាសហព័ន្ធមួយដែលព្រះសហគមន៍កាតូលិកបានបង្កើតឡើង១៩៦៩ ក្រោយវ៉ាទីកង់ទី២ ដើម្បីធ្វើការ ដោយយកព្រះគម្ពីរជាប្រភពនៃសកម្មភាពគ្រប់យ៉ាង រួមមានពិធីបុណ្យ អប់រំជំនឿ មនុស្សធម៌ ( ការីតាស )។ សហព័ន្ធនេះមានប្រទេសចំនួន១២៦ ត្រូវបានបង្កើតឡើងដើម្បីជួយដល់អ្នកបកប្រែគម្ពីរ បោះពុម្ព ផ្សព្វផ្សាយគម្ពីរក្នុងចំណោមគ្រីស្តបរិស័ទដើម្បីឲ្យពួកគាត់បានស្គាល់ព្រះគម្ពីរ។

នៅមុនមហាសន្និបាតវ៉ាទីកង់ទី២ ព្រះសហគមន៍កាតូលិកមិនអនុញ្ញាតឲ្យគ្រីស្តបរិស័ទអានគម្ពីរដោយផ្ទាល់ខ្លួននោះទេ ហើយព្រះគម្ពីរ និងពិធីបុណ្យនានាសុទ្ធតែជាភាសាឡាតាំង ព្រោះគ្មានការបកប្រែគម្ពីរណាមួយបានធ្វើឡើងតាមភាសានៃប្រទេសនីមួយៗនោះទេ។

សហព័ន្ធក៏បានលើកទឹកចិត្តឲ្យបង្កើតក្រុមសិក្សាតូចៗសម្រាប់ការអានព្រះគម្ពីរ ក៏ដូចជាការបង្កើតឧបករណ៍អប់រំសម្រាប់ប្រើប្រាស់ក្នុងប្រទេសនីមួយៗ។ សហព័ន្ធនេះ ត្រូវបានរៀបចំដំបូងក្រោមឈ្មោះ សហព័ន្ធកាតូលិកពិភពលោកសម្រាប់ព្រះគម្ពីរ( The World Catholic Federation for the Biblical Apostolate ) នៅឆ្នាំ 1969 ប៉ុន្តែក្រោយមកបានក្លាយជាសហព័ន្ធព្រះគម្ពីរកាតូលិក នៅឆ្នាំ ១៩៩០ នៅក្នុងសន្និបាតពេញអង្គលើកទីបួនដែលរៀបចំឡើងនៅប្រទេសកូឡុំប៊ី។

សព្វថ្ងៃនេះសហព័ន្ធព្រះគម្ពីរកាតូលិក មានលោកកាឌីណាល់អាន់តូញ៉ូ តាក្លេជាអ្នកទទួលខុសត្រូវ។ រហូតមកដល់ពេលនេះ សហព័ន្ធនេះមានអាយុកាល ៥០ឆ្នាំមកហើយ៕



*សម្ដេច ប៉ាប ហ្វ្រង់ស៊ីស។ រូបភាព៖ បរទេស*

# អបអរសាទរ

# ខួប៥០ឆ្នាំ

# នៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យ

«សូមព្រះជាម្ចាស់ ប្រទានពរដល់លោកបូជាចារ្យទាំងបីអង្គ សូមឲ្យមានកម្លាំងកាយ ស្មារតី សុខភាពល្អ និងអាយុយឺនយូរ ដើម្បីបន្តបេសកកម្ម ប្រកាសដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ត ដល់ប្រជាជាតិនានា»។



លោក តូនី វេនត្រាមីន



លោក សិលា ឡេវ៉ាន់ទីន



លោក ពិសេ រ៉ូប៊ីត (បប់)

គោរពជូនពរពីការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក


Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវេរីតាស់អាស៊ីខេមរភាសា

សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយវិទ្យុ FM នៅភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្តាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com និង www.catholiccambodia.org
- លោកអ្នក ក៏អាច Follow facebook ផ្លូវការរបស់យើងតាមរយៈ www.facebook.com/RVAKHMER/

**តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវេរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុង (Khmer Live Audio)។

Radio Varitas Asia

Khmer Live audio

ឬ តាមរយៈគេហទំព័រ៖ http://rvakhmer.com